មជ្ឈមណ្ឌលឯកសារកម្ពុជា

# សម្ភាសន៍ជាមួយ ខៀវ គួន ភេទប្រុស អាយុ៦៣ឆ្នាំ

# មុខងារសម័យខ្មែរក្រហមៈ “យោធា”

# សព្វថ្ងៃរស់នៅភូមិអូរគគីរក្រោម ឃុំលំទង ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ

ថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០១២

សម្ភាសន៍ដោយៈ ហ៊ិន សុផានី

០១:៣៦:១២

៧៧ទំព័រ

ផានី : ថ្ងៃនេះថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០១២ ។ ខ្ញុំឈ្មោះ ផានី ខ្ញុំមកពីខាងមជ្ឈមណ្ឌលឯកសារកម្ពុជា ។ កន្លែងអង្គការពួកខ្ញុំ ធ្វើការទាក់ទងស្រាវជ្រាវចងក្រងប្រវត្តិសាស្ត្រសម័យខ្មែរក្រហម ។ ហើយពួកខ្ញុំចុះមកភូមិលោកតានេះ ចង់សាកសួរលោកតាផ្ទាល់ ពីបទពិសោធន៍របស់លោកតាៗបានឆ្លងកាត់តាំងពីមុនរហូតមកដល់ឥឡូវ ហើយហេតុអីបានមករស់នៅទីនេះ ។ ហើយរឿងរ៉ាវអស់នឹង ចៅសុំយកទៅធ្វើជាសៀវភៅមួយដែលមានឈ្មោះថាសៀវភៅមគ្គុទេសទេសចរណ៍ប្រវត្តិសាស្ត្រតំបន់អន្លង់វែង សម្រាប់ឲ្យក្មេងៗ ក៏ដូចកូនចៅឬអ្នកដែលគេអត់ស្គាល់ពីអន្លង់វែងឲ្យគេបានដឹង បានព្វុ ។ ចឹងជាដំបូងសុំថតជាសម្លេងក៏ដូចជារូបថតអីចឹងបានទេលោកតា?

គួន : បានតើ ។

ផានី : លោកតាមានឈ្មោះអីដែរ?

គួន : ខៀវ គួន ។

ផានី : ឆ្នាំនឹងអាយុប៉ុន្មានហើយលោកតា?

គួន : ៦៣ ។

ផានី : សព្វថ្ងៃលោកតាធ្វើអីដែរ?

គួន : ធ្វើស្រែ ។

ផានី : សព្វថ្ងៃលោកតារស់នៅណា?

គួន : នៅអូរគគីរក្រោម ។

ផានី : ឃុំអីគេ?

គួន ៖ ឃុំលំទង ។

ធានី ៖ ស្រុក?

គួន ៖ ស្រុកអន្លង់វែង ។

ធានី ៖ ខេត្ត?

គួន ៖ ខេត្តឧត្តរមានជ័យ ។

ធានី ៖ គ្រួសារលោកតាឈ្មោះអីដែរ?

គួន ៖ ខៀន រី ។

ធានី ៖ ឆ្នាំនឹងគាត់អាយុប៉ុន្មានហើយ?

គួន ៖ ៤៨ ។

ធានី ៖ គាត់មានស្រុកកំណើតនៅណា?

គួន ៖ នៅគិរីមាន្នន ព្រះដាក់យើង ។

ធានី ៖ ភូមិអីគេ?

គួន ៖ ភូមិគិរីមុន្នន ដាក់តែប្រដាក ។

ធានី ៖ នៅក្នុងប្រដាក?

គួន ៖ នៅភូមិគិរីមាន្នន ប៉ុនឃុំប្រដាក ។

ធានី ៖ ស្រុកអីគេនឹង?

គួន ៖ ស្រុកអីគេ ស្រុកបន្ទាយស្រី ។

ធានី ៖ ខេត្តសៀមរាប?

គួន ៖ បាទ!

ធានី ៖ លោកតាមានកូនចៅប៉ុន្មាននាក់ដែរ?

គួន ៖ ខ្ញុំកូន៦ ។

ធានី ៖ ស្រីប៉ុន្មានប្រុសប៉ុន្មាន?

គួន ៖ ស្រី៤ ប្រុស២ ។

ធានី ៖ គាត់នៅរស់ទាំងអស់ទេ?

គួន ៖ ហ្នឹងហើយ ។

ធានី ៖ លោកតាមានស្រុកកំណើតនៅណាដែរ?

គួន ៖ ខ្ញុំនៅស្រុកពួក ។

ធានី ៖ នៅភូមិអីគេ?

គួន ៖ ភូមិឈូក ។

ធានី ៖ ឃុំអីគេ?

គួន ៖ ត្រីញ័រ ។

ធានី ៖ ឃុំត្រីញ័រ ស្រុកពួក ខេត្តសៀមរាប ។ ឪពុកលោកតាឈ្មោះអីដែរ?

គួន ៖ កើត គួន ។

ធានី ៖ ហ៎! លោកតាឈ្មោះខៀវ គួន គាត់ឈ្មោះ?

គួន ៖ ជីតា។ ខៀវ គួន ដល់ឪពុកឈ្មោះ កើត ។

ធានី ៖ ចុះលោកឈ្មោះអី?

គួន ៖ ខ្ញុំឈ្មោះ គួន។ អានេះខ្ញុំដាក់នាមត្រកូលជីតា អត់មានដាក់នាមត្រកូលឪពុកទេ ។

ធានី ៖ ប៉ុន្តែលោកតាឈ្មោះ?

គួន ៖ គួន ។

ធានី ៖ គួន?

គួន ៖ បាទ!

ធានី ៖ ដល់ពេលជីតាលោកតាឈ្មោះ?

គួន ៖ ខៀវ ។

ធានី ៖ ដល់ពេលឪពុកលោកតាឈ្មោះ?

គួន ៖ ឪ កើត ។

ធានី ៖ កើត ខៀវ?

គួន ៖ បាទ!

ធានី ៖ កើត ខៀវ?

គួន ៖ កើត ខៀវ ។

ធានី ៖ គាត់នៅរស់ទេ?

គួន ៖ ស្លាប់អស់ហើយ ។

ធានី ៖ ស្លាប់ពីអង្កាល់ដែរ?

គួន ៖ ស្លាប់តាំងពីសម័យកសាង ។

ធានី ៖ ដោយសារអីដែរ?

គួន ៖ ទេ! ខ្ញុំនៅមុខនឹងមិនសូវដឹង ។

ធានី ៖ គាត់ស្លាប់នៅកន្លែងណា?

គួន ៈ ស្លាប់នៅនឹងផ្ទះ ។

ធានី ៈ សម័យកសាង សម័យ៣ឆ្នាំនឹង?

គួន ៈ បាទ! សម័យប៉ុល ពត ។

ធានី ៈ ហើយកាលនឹងគាត់ស្លាប់នៅណា?

គួន ៈ នៅភូមិ ឃុំត្រីញ័រ ។

ធានី ៈ ភូមិឈ្មោះនឹង?

គួន ៈ បាទ!

ធានី ៈ ម្ដាយលោកតាឈ្មោះអីដែរ?

គួន ៈ សូ សឿម ។

ធានី ៈ សូ សឿម?

គួន ៈ បាទ!

ធានី ៈ គាត់នៅរស់ទេ?

គួន ៈ ស្លាប់អស់ហើយ ។

ធានី ៈ ស្លាប់ពេលណាដែរ?

គួន ៈ សាប់ពេលអង្គាល់ហ៉េ! ចប់សង្គ្រាម ។

ធានី ៈ ពេលវៀតណាមចូលនឹង?

គួន ៈ បាទ! ពេលនឹង ។

ធានី ៈ លោកតាមានបងប្អូនប៉ុន្មាននាក់ដែរ?

គួន ៈ បងប្អូន៣នាក់ ។

ធានី ៈ ស្រីប៉ុន្មាន ប្រុសប៉ុន្មាន?

គួន ៈ ស្រី១ ប្រុស២ ។

ធានី ៈ លោកតាកូនទីប៉ុន្មានដែរ?

គួន ៈ ខ្ញុំកូនពៅ ។

ធានី ៈ គាត់នៅរស់ទេ បងប្អូនទាំង៣នាក់?

គួន ៈ នៅតែ១ទេ ។

ធានី ៈ នៅមួយណាទៅ?

គួន ៈ នៅ២នាក់ខ្ញុំ ។

ធានី ៈ ម្នាក់ទៀតស្រីហើយប្រុស?

គួន ៖ នៅប្រុស ។

ធានី ៖ ចឹងម្នាក់ស្រីស្លាប់ហើយ?

គួន ៖ ស្លាប់ ។

ធានី ៖ ស្លាប់ដោយសារអីគេ?

គួន ៖ ជម្ងឺរោគា ។

ធានី ៖ ពីអន្តាល់?

គួន ៖ ស្លាប់៤-៥ឆ្នាំហើយ ។

ធានី ៖ គាត់បងធំ បងស្រី?

គួន ៖ បន្ទាប់ទេ ។

ធានី ៖ បន្ទាប់លោកតា?

គួន ៖ អឺ!

ធានី ៖ ចឹងនៅបងប្រុស នៅស្រុកកំណើត?

គួន ៖ នៅទឹកវិល ។

ធានី ៖ លោកតាបានរៀនបានសូត្រអីទេ?

គួន ៖ ខ្ញុំមិនដែលបានរៀនអីទេកើតមក ។

ធានី ៖ ចឹងចេះអានអក្សរអត់?

គួន ៖ អត់ទេ ។

ធានី ៖ ម៉េចចឹងលោកតា ម៉េចអត់បានរៀនចឹង?

គួន ៖ អាឡែងតែខ្ញុំមានណា ខ្ញុំពៅ ខ្ញុំមើលតែគោ មានដែលបានរៀន ។ រៀនៗតែរៀនមិនចូល រៀនតិចទៅរត់ទៅមើលគោ ។

ធានី ៖ ម៉េចចឹង បងៗគាត់ទៅណា បានលោកតាមើលគោ?

គួន ៖ បងគេរៀន គេធ្វើគ្រូនៅសៀមរាប ។

ធានី ៖ បងប្រុស បងស្រី?

គួន ៖ បាទ!

ធានី ៖ ទាំងពីរ?

គួន ៖ ហ្នឹងហើយ ។

ធានី ៖ ដល់ពេលលោកតាអត់បានទេ ជាប់មេលគោនៅភូមិ?

គួន ៖ អឺ! នៅភូមិ ។

ធានី : អត់បានរៀន ។ កាលនឹងអត់ចង់រៀន ឬក៏រៀនអត់កើត?

គួន : ចង់ដែរ ប៉ុន្តែទៅបានម៉ាថ្ងៃ២ គាត់ដកឲ្យ ដែលគាត់ចាស់ហើយ ដកឲ្យមកមើលគោ ។

ធានី : លោកពុកលោកតា?

គួន : បាទ! សុខចិត្តបោលឯនោះ ។

ធានី : សុខចិត្តនៅមើលគោ?

គួន : បាទ!

ធានី : ហើយនៅនឹងរហូតដល់ពេលណា នៅមើលគោនៅភូមិរហូត?

គួន : នៅទាល់អាយុ២២ បានខ្ញុំចូលធ្វើទាហាន ។

ធានី : ២២ឆ្នាំ ចូលធ្វើទាហាន?

គួន : បាទ! ទាហានវ៉ៃ លន់ នល គេបង្ខំទេ ។

ធានី : លោកតាធ្វើទាហានខ្មែរក្រហម?

គួន : បាទ!

ធានី : កាលនឹងលោកតាអាយុ២២ឆ្នាំ កាលនឹងប្រហែលឆ្នាំប៉ុន្មានលោកតាដែលចូលធ្វើទាហាន?

គួន : មិនដឹងណាទេ ភ្លេចទៅ ។

ធានី : រកនឹកមើលលោកតា កាលនឹងសម្តេចយើងត្រូវបានគេទម្លាកឥឡូវ?

គួន : បាទ!

ធានី : ទម្លាក់ហើយ?

គួន : ហ្នឹង ។

ធានី : ទម្លាក់ហើយភ្លាមបានលោកតាចូល ឬម៉េច?

គួន : ទម្លាក់ហើយបានចូល ។

ធានី : ទម្លាក់ហើយភ្លាមបានប៉ុន្មានឆ្នាំ បានលោកតាចូល?

គួន : ទម្លាក់ហើយបានម៉ាឆ្នាំ ។

ធានី : ចឹងអាចថា៧១?

គួន : បាទ! ៧១ ។

ធានី : ព្រោះអី៧០លន់ នល់ គាត់ទម្លាក់សម្តេចសីហនុចុះ?

គួន : ហ៊ើ! អាចចូលធ្វើទាហាន៧៤ ។

ធានី : ៧៤?

គួន : បាទ! ៧៤ ។

ធានី ៖ ១៩៧៤ លោកតាស្ម័គ្រចិត្តចូលធ្វើទាហាន?

គួន ៖ ទេ! គេបង្ខំ ។

ធានី ៖ អ្នកណាគេបង្ខំលោកតាទៅ ឈ្មោះអីគេដែរថា?

គួន ៖ អូ! អត់ចាំឈ្មោះគេទេ ស្លាប់អស់ហើយ ។

ធានី ៖ គាត់ហ្នឹងអ្នកនៅភូមិយើងដែរ?

គួន ៖ បាទ! មេឃុំ ។

ធានី ៖ មេឃុំ លោកតារកនឹកមើលមេឃុំអីគេ មេឃុំនឹងឈ្មោះអី?

គួន ៖ អៀមៗ ។

ធានី ៖ មេឃុំត្រីញ៉ូរនឹង?

គួន ៖ បាទ!

ធានី ៖ ឈ្មោះ អៀម ។ បើយើងអត់ទៅយ៉ាងម៉េចទៅលោកតា?

គួន ៖ អត់ទៅគេបង្ខំឲ្យទៅដែរ ។

ធានី ៖ បើយើងអត់ទៅមានបញ្ហាអីកើតឡើង?

គួន ៖ គេធ្វើទុក្ខម៉ែឪ ។

ធានី ៖ តែចុះបងប្អូនលោកតាទៅទាំងអស់គ្នា ឬទៅតែលោកតា?

គួន ៖ ទៅតែខ្ញុំទេ បងប្អូនខ្ញុំនៅសៀមរាប ផុត ។

ធានី ៖ នៅតែលោកតា?

គួន ៖ បាទ! គេនៅខាងលន់ នល់ ។

ធានី ៖ ចឹងបែកគ្នា យើងអត់មានទទាក់ទំនងរវាងបងប្អូនជាមួយឪពុកម្ដាយទេ?

គួន ៖ បាទ!

ធានី ៖ បងប្អូនលោកតា ហើយនិងឪពុកម្ដាយលោកតា អត់ទាក់ទងគ្នាទេ?

គួន ៖ បាទ!

ធានី ៖ ចឹងលោកតាធ្វើសង្គ្រាមវៃជាមួយ?

គួន ៖ វៃជាមួយ ។ កាលនោះវាដែលបានដឹងថាបងថាប្អូន ។

ធានី ៖ ម៉េចចឹង?

គួន ៖ ប៉ុនគេនៅក្នុង គេអត់បានធ្វើទាហានដែរ គេធ្វើគ្រូ ។

ធានី ៖ ប៉ុន្តែលោកតា ត្រូវគេបង្ខំឲ្យចូលធ្វើទាហាន?

គួន ៖ នោះ ។

ធានី :	ដល់ពេលធ្វើទាហានៗ នៅកន្លែងណាទៅ?

គួន :	ខ្ញុំធ្វើទាហាននៅមុខអង្គរដែរ ។

ធានី :	ចូលទៅដល់នៅ?

គួន :	ចូលទៅដល់នៅវាលវង្ស ។

ធានី :	វាលវង្សកាប៉ាល់ហោះនឹង?

គួន :	បាទ!

ធានី :	ចូលទៅដល់ភ្លាមគេឲ្យធ្វើទាហានភាម ឬយើងទៅហាត់ទាហានសិន?

គួន :	ហាត់៣ខែ ។

ធានី :	ហាត់៣ខែ ហាត់នឹងហាត់ម៉េចខ្លះទៅ?

គួន :	អ! ហាត់ដែលរៀនទាហានដែលប្រាប់កើត ក្រាបលូន ។

ធានី :	ហាត់ ពិបាកខ្លាំង កាលយើងចូលដំបូង?

គួន :	អូ! ហាត់ លូន ក្រាបវាស់ៗល្ងាច ហាត់៣ខែចេញ ។

ធានី :	ហាត់៣ខែហើយបានទៅធ្វើ?

គួន :	ចេញមកច្បាំង និងបាញ់គ្នាវាលវង្ស ។

ធានី :	ចេញមកច្បាំងម៉ង?

គួន :	បាទ!

ធានី :	ចឹងកាលហាត៣ខែ ហាត់នៅណាវិញ?

គួន :	ហាត់នៅដំដែក នៅវត្តដំដែក ។

ធានី :	ហើយក៏ចេញមកច្បាំងនៅវាលវង្សយន្តហោះ?

គួន :	បាទ! កន្លែងស្នាក់ការនៅគោកគ្នោត ។

ធានី :	ស្នាក់កាលនៅគោកគ្នោតនៅម្តុំនឹងដែរ?

គួន :	នៅជិត ។

ធានី :	ហើយទៅច្បាំងគ្នាជាមួយទាហានលន់ នល់?

គួន :	បាទ!

ធានី :	ភ័យទេលោកតា ច្បាំងដំបូង?

គួន :	ភ័យដំបូងមេឃឡើងងងឹត ឡើងខ្មៅ ។

ធានី :	ហើយលោកតាត្រូវនៅវៃនៅសមរភូមិជាមួយគេម៉ង?

គួន :	បាទ!

ធានី : ចឹងលោកតាធ្វើម៉េចទៅ?

គួន : ទេ! គិតឃើញម៉េច យើងមេច ។

ធានី : ឃើញគេមេច ធ្វើតាមគេទៅ?

គួន : បាទ! គិតឃើញគេរម៉េច យើងនៅរស់ គេទៅកើតយើងទៅមិនកើត ។

ធានី : បេះគេទៅកើត យើងទៅកើតដែរ?

គួន : បាទ!

ធានី : ហើយបេះទៅច្បាំងជាមួយគេជាមួយឯង?

គួន : ហ្អឹង ។ ទៅបើចិត្តខ្លួនឯងមិនចង់ធ្វើទេ ទាហាន គ្មានគេឲ្យកូនទេ ទាហាន ។

ធានី : ម៉េចចឹង?

គួន : ចុះទាហាន ដឹងថ្ងៃណាងាប់ ។

ធានី : ដល់ពេលទៅធ្វើទាហានច្បាំងដំបូង លើកដំបូងហើយយើងរៀងភ័យ?

គួន : បាទ!

ធានី : ទៅណាទៀតទៅពេលច្បាំង? ច្បាំងឈ្នះហើយចាញ់កាលនឹង?

គួន : ទេ! អារឿងបាញ់គ្នា ជួនឈ្នះ ជួនចាញ់ ។

ធានី : តែពេលលោកតាច្បាំងនៅវាលវង្សនឹង ឈ្នះហើយចាញ់?

គួន : ឈ្នះ រកចាញ់គេ ងាប់អស់១២ ។

ធានី : អស់១២នាក់?

គួន : បាទ!

ធានី : ហើយនៅទាហាននឹងនៅកងពលអីដែរ កាលនឹង?

គួន : កងពល១៥ ។

ធានី : កងពល១៥នឹងនៅប្រចាំខេត្តសៀមរាបយើង ឬក៏យ៉ាងម៉េចដែរ?

គួន : បាទ! ប្រចាំខេត្តសៀមរាប ។

ធានី : អានឹងគេហៅប្រចាំភូមិភាគហើយអត់ទេ?

គួន : បាទ! នៅកងពលធំគេឈ្មោះ តា ជាត ។

ធានី : តែកងពល១៥ កងពលធំ?

គួន : បាទ!

ធានី : ចុះកងពលលេខប៉ុន្មាន?

គួន : កងពលធំអី កងពលតូច ។

ធានី ៖ កងពលតូចលេខ១៥នឹងឈ្មោះ ជាតិ?

គួន ៖ បាទ!

ធានី ៖ មេរបស់លោកតា?

គួន ៖ អឺ!

ធានី ៖ ចុះកងពលធំ?

គួន ៖ ខ្ញុំអត់ស្គាល់ដែរ ។

ធានី ៖ មេដូចថាកងពលនឹងប្រចាំអីគេ?

គួន ៖ កងពលធំ មេកងពលធំមានតែ តា ពក យើង ។

ធានី ៖ តា ពក, កែ ពក?

គួន ៖ អឺ!

ធានី ៖ ចឹងអានឹងខាងកងពលលេខប៉ុន្មាន?

គួន ៖ ខ្ញុំភ្លេចដែរ ខ្ញុំយុទ្ធជន មិនដែលបានធ្វើអី ។

ធានី ៖ ឈ្មោះ កែ ពក ប្រចាំភូមិភាគអីទេលោកតា?

គួន ៖ អត់ដឹងដែរ បើខ្ញុំមិនសួរបាន ។

ធានី ៖ គ្រាន់ដឹងថាកងពលតូច គេហៅវរសេនាតូច?

គួន ៖ បាទ! ហ្នឹង ។

ធានី ៖ លេខ១៥ឈ្មោះ ជាតិ?

គួន ៖ ហ្នឹង ។

ធានី ៖ តែដល់ពេលកងពលធំប្រចាំនឹងម៉ង គឺឈ្មោះ កែ ពក?

គួន ៖ បាទ!

ធានី ៖ ហើយម៉េចទៀតទៅលោកតា វ៉ៃនៅនឹងរហូតដល់ពេលណាបានឈប់វ៉ៃ?

គួន ៖ ឈប់ទាល់ចប់វ៉ៃលន់ នល់ដាច់ ។

ធានី ៖ វ៉ៃ លន់ នល់ ឈ្នះ?

គួន ៖ បាទ!

ធានី ៖ លន់ នល់ ឈ្នះឆ្នាំប៉ុន្មានលោកតា?

គួន ៖ នេះ៧៥ ។

ធានី ៖ ១៩៧៥ លន់ នល់ ចាញ់?

គួន ៖ លន់ នល់ ចាញ់ ។

ធានី ៖ ហើយលោកតាទៅណាវិញ ពេលនឹង ទ័ពលោកតា?

គួន ៖ ទ័ពខ្ញុំនៅសាលាលីសសេ ជិតសៀមរាប ខាងជើងសៀមរាប ។

ធានី ៖ វិទ្យាល័យសៀមរាបខាងជើង?

គួន ៖ បាទ!

ធានី ៖ មិញលោកតាលោកតាមុន នៅ៧៨នឹង ពូលោកតានិយាយថាមុនពេលនៅ៧៨ លោកតាបានទៅយាមនៅអង្គរវត្តដែរ?

គួន ៖ យាម ។

ធានី ៖ យាមខាងណាអង្គរវត្ត?

គួន ៖ នៅអង្គរធំ ។

ធានី ៖ ខាងណាទៅ?

គួន ៖ អង្គរធំ អង្គរវត្ត ។

ធានី ៖ យាមនឹងយាមយ៉ាងម៉េច?

គួន ៖ យាមដែលទាហានវាមក ។

ធានី ៖ ទាហានវាមក?

គួន ៖ ដែលយើងទៅវើៗខាងនោះអង្គរ ខ្សែលីញតាមនេះ ។

ធានី ៖ ពេលយាមនឹង គេយើងយាមកុំឲ្យទាហាន លន់ នល ចូលទេ?

គួន ៖ បាទ!

ធានី ៖ យើងយាមនៅនឹងធ្វើអី បើមានតែប្រាសាទនឹង?

គួន ៖ ចុះគេបទបញ្ជាគេឲ្យធ្វើហើយ ។

ធានី ៖ តែមានធ្លាប់ឃើញគណៈប្រតិភូអីគេមកអង្គរទេ?

គួន ៖ មកដែរ ប៉ុនអត់ធ្វើអីទេ ។

ធានី ៖ តែលោកតាបានឃើញពួកគាត់?

គួន ៖ បាទ!

ធានី ៖ ពេលនឹងបានឃើញ ពេលនឹងធ្លាប់ឃើញសម្តេចគាត់យាងទៅលេង?

គួន ៖ ទេ! ពេលសម្តេចមក ខ្ញុំនៅតែឯនេះ ពេលសម្តេចមកខ្ញុំនៅវាលវង្ស ។

ធានី ៖ តែបានដឹងថាគាត់អញ្ជើញមកដែរ?

គួន ៖ បាទ!

ធានី ៖ ដល់ពេលបន្ទាប់មកទៀត អ្នកណាមកទៀត?

គួន ៖ អត់ដឹងរឿង ខ្ញុំទៅនោះបណ្ដោយ ។

ធានី ៖ តែធ្លាប់ឃើញគាត់?

គួន ៖ មិនដែលបាននេះ មិនដែលបានឃើញទេ ប៉ុន្តែគេថា ។

ធានី ៖ តែដល់ពេល៧/៨លោកតានៅឃុំមនឹងដែរ តែអត់មានអ្នកណាមកលេងទៀតទេ?

គួន ៖ អត់ទេ ។

ធានី ៖ តែនៅការពារៗយ៉ាងម៉េចពេលនឹង?

គួន ៖ ការពារកុំឲ្យទាហានវាចូលមក ។

ធានី ៖ ហើយមានឆ្នក់មកម្ដងម្កាលអីទេ?

គួន ៖ បាទ! វាចូលមកម្ដងម្កាល ។

ធានី ៖ ហើយចូលមកធ្វើស្អីទៅ?

គួន ៖ បាញ់គ្នានៅនោះ ។

ធានី ៖ នៅអង្គរនឹង?

គួន ៖ នៅអង្គរវត្ត ។

ធានី ៖ ហើយដល់ពេលឆ្នាំ៧/៩ដាច់ទៅ កងទ័ពលោកតា នៅខាងដើងវិទ្យាល័យសៀមរាប?

គួន ៖ បាទ! នៅបានមួយខែ គេបញ្ជូនមកនៅក្រឡាញ់-កំពង់ថ្កូវយើង ។

ធានី ៖ ទៅក្រឡាញ់ធ្វើអីលោកតា?

គួន ៖ គេបញ្ជូនជាដំណាក់ៗចេញពីក្រឡាញ់-កំពង់ថ្កូវបានមកនេះ ។

ធានី ៖ ចឹងទៅក្រឡាញ់-កំពង់ថ្កូវ ទៅធ្វើអីគេលោកតា?

គួន ៖ ទាហានប្រចាំទិសនឹង ៦ខែ ។

ធានី ៖ លោកតាធ្វើទាហានប្រចាំទិសនឹង?

គួន ៖ បាទ!

ធានី ៖ ប្រចាំទិសក្រឡាញ់នឹង?

គួន ៖ បាទ!

ធានី ៖ ហើយទាហានប្រចាំទិសនឹង ធ្វើការងារអីខ្លះទៅ?

គួន ៖ គ្មានធ្វើការងារអីទេ ធ្វើស្រែធ្វើអ៊ធម្មតា ។

ធានី ៖ តែគេឲ្យហៅទាហាន?

គួន ៖ បាទ!

ធានី ៖ ទាហាននៅវរសេនាតូចដដែល?

គួន :	បាទ!

ធានី :	កងពលដដែល?

គួន :	អត់មានច្បាំងឯណា ។

ធានី :	ហើយដល់ពេលនៅកំពង់ថ្កូវដល់ប៉ុន្មានបាន បានគេដាក់មកទៀត?

គួន :	នៅបានមួយខែបានគេបញ្ជូនមកនេះ ។

ធានី :	មួយខែក្រោយ មកណា មកអន្លង់វែងយើងម៉ង?

គួន :	បាទ!

ធានី :	មួយខែនឹង គឺយើងមកអន្លង់វែង?

គួន :	អឺ!

ធានី :	តាមផ្លូវណាទៅលោកតា?

គួន :	អត់កាលនោះព្រៃទេរ តាមនេះដែលមានភូមិ ។

ធានី :	ចឹងធ្វើម៉េចមកដល់?

គួន :	គេទាក់ទងប្រជាជនឲ្យនាំផ្លូវ ។

ធានី :	ទាក់ទងប្រជាជនខាងណា?

គួន :	ខាងចុងកាល់-សំរោង ។

ធានី :	ខាងណាគេអ្នកទាក់ទង លោកតាដឹងទេ?

គួន :	មេគេទាក់ទង ។

ធានី :	មេអីឈ្មោះ?

គួន :	ឈ្មោះ ជាតិ ។

ធានី :	ឈ្មោះ ជាតិ នឹងអ្នកទាក់ទង?

គួន :	ហ្នឹង ។

ធានី :	ហើយខាងនឹងម៉េចយើងត្រូវមកនឹងវិញ?

គួន :	គេបញ្ជូនមកនៅព្រំដែន ។

ធានី :	មកនៅអន្លង់វែងនឹងព្រំដែនដែរ?

គួន :	នៅអន្លង់វែង ប៉ុន្តែទីស្នាក់ការនៅអន្លង់វែង យើងទៅធ្វើការលើភ្នំ ។

ធានី :	យើងឡើងលើភ្នំវិញ?

គួន :	បាទ!

ធានី :	តែលោកតា កាលនឹងលោកតាអត់ស្គាល់ផ្លូវផង ធ្វើម៉េចមកដល់?

គួន ៖ បេះតែមកតាមគេ ។

ផានី ៖ អ្នកណាគេអ្នកនាំផ្លូវ?

គួន ៖ អ្នកប្រជាជន ។

ផានី ៖ ស្គាល់ឈ្មោះគាត់ទេ ដែលនាំផ្លូវ?

គួន ៖ អត់ស្គាល់ទេ ស្លាប់អស់ហើយ ។

ផានី ៖ ស្លាប់អស់ហើយ?

គួន ៖ អឺ!

ផានី ៖ តែគ្រាន់ដឹងថា ប្រជាជននឹងគាត់អ្នកនាំមក?

គួន ៖ យើងពីដើមដើរផ្លូវនេះតើ ។

ផានី ៖ ដើរផ្លូវណាទៅ?

គួន ៖ ផ្លូវចាស់លំទងនេះ ។

ផានី ៖ ចឹងលោកតាអាចជួយរៀបរាប់តិចបានទេ ថាពេលដែលលោកតាធ្វើដំណើរពីកំពង់ថ្កូវ-ក្រឡាញ់នឹង មកអន្លង់វែង យើងត្រូវធ្វើដំណើរយ៉ាងម៉េច យើងត្រូវដើរតាមផ្លូវណា?

គួន ៖ ឡាន ។

ផានី ៖ ជិះឡាន?

គួន ៖ បាទ! ឡានមកចុះនៅឈើក្រំ បានមកនេះ ឡាន២គ្រឿងមកនេះ ។

ផានី ៖ ចឹងជិះឡានចូលដល់នេះដែរ?

គួន ៖ បាទ! ឡាន២គ្រឿង អាត្រាក់ម៉ាគ្រឿងមកជាប់នឹងអូរគគីរនេះ ម៉ាវស្សា ។

ផានី ៖ យូរដែរ?

គួន ៖ ទាល់តែខែទឹកសម្រក់បានយើងដើរបាន បានដឹកអង្ករទៅ ។

ផានី ៖ ចឹងកាលពេលលោកតាមក ជិះឡាន ហើយក៏ដើរ?

គួន ៖ ដើរផង អាអ្នកបើកនាំផ្លូវមុនឡាន ។

ផានី ៖ ឡានទៅមុនចឹង?

គួន ៖ ឡានមកជាមួយនាំផ្លូវមួយ ។

ផានី ៖ ចឹងឡានជិះឡានមកនឹងយើងដើរតាមស្នាមកង់ឡាននឹងទៅ?

គួន ៖ បាទ!

ផានី ៖ ចឹងកាលពេលលោកតានៅកំពង់ថ្កូវ មកដើរតាមផ្លូវណា តាមសំរោង?

គួន ៖ សំរោង ។

ធានី ៖ សំរោងហើយទៅដល់?

គួន ៖ ធ្លាក់មកឈើក្រ ។

ធានី ៖ ឈើក្រុំកន្លែងណាវិញ?

គួន ៖ ឈើក្រុំ កូនគ្រៀលខាងជើងសំរោង ។

ធានី ៖ ហើយរហូតដើរមកតាមផ្លូវណាទៀត?

គួន ៖ ដើរមកធ្លាក់មកភូមិបុស ។

ធានី ៖ ភូមិបុស ហើយទៅណាទៀតទៅ?

គួន ៖ មកនេះ ធ្លាក់មកអូរផាលមក ។

ធានី ៖ អូរផាល?

គួន ៖ អូរផាល ធ្លាក់មកលំទង តាដេវ ។

ធានី ៖ លំទង តាដេវ អត់មានត្រពាំងប្រាសាទអីកាលនឹង?

គួន ៖ អត់ទេ ។

ធានី ៖ អត់មានឈ្មោះនឹងណាកាលនឹង?

គួន ៖ អត់មានទេ មានតែតាដេវ លំទង ។

ធានី ៖ ចឹងលោកតា ដើរតាមផ្លូវនឹងមករហូតមកដល់លំទងយើង?

គួន ៖ កន្លះខែបានមកដល់នេះ ។

ធានី ៖ ហើយតាមផ្លូវយ៉ាងម៉េចដែរលោកតា អាចជួយប្រាប់តិចបានទេ?

គួន ៖ ទេ! អត់មានអីតាមផ្លូវធម្មតា ។

ធានី ៖ ដូចថាផ្លូវយើងអ្នកភូមិចេះ ឬក៏ផ្លូវព្រៃ?

គួន ៖ ផ្លូវព្រៃគេសុទ្ធ ផ្លូវចាស់ ផ្លូវរទេះគេ ។

ធានី ៖ ផ្លូវរទេះ?

គួន ៖ បាទ! យើងមកតាមផ្លូវរទេះ ។

ធានី ៖ ពិបាកទេលោកតា?

គួន ៖ ពិបាក ។

ធានី ៖ ពិបាកដើរផងអីផង?

គួន ៖ ដើរផង ។

ធានី ៖ ហើយដើរប៉ុន្មានថ្ងៃសម្រាកម្តង?

គួន ៖ ដើរចេះតែមកតិចៗមួយថ្ងៃខិតតិចៗ កន្លះខែបានដល់ ។ មកមុនដំបូងឆ្ងាយ ហើយអ្នកភូមិនេះបើគេរៀងចង្អុលផ្ដេចចេះឆ្ងាយ បើចង្អុលរៀងបន្តក់ជិតទេ ។ ដូចខ្ញុំមកពីត្រពាំងតាវ សួរគេ អ៊ឹងផណាអន្លង់វែងឆ្ងាយ ឬអត់? ទៅដល់នេះ លើកដល់ត្រង់នេះ ។

ធានី ៖ គាត់និយាយចឹង?

គួន ៖ បាទ! ដើរឡើង២ថ្ងៃ បានដល់នឹង ។

ធានី ៖ ចឹងកាលពេលអ៊ំដើរមកតាមផ្លូវនឹង អ្នកភូមយើងមានរស់នៅហើយៗ?

គួន ៖ បាទ! នៅគ្រប់ភូមិ ។

ធានី ៖ មិញលោកតាដើរមើល?

គួន ៖ គេដើរខាងលំទង ខាងខ្ញុំនាំផ្លូវដើរខាងលំទង ។

ធានី ៖ មញលោកតាថាដើរៗដំបូង ដើរទៅភូមិ?

គួន ៖ ភូមិបុស ។

ធានី ៖ ភូមិបុសនឹងមានប្រជាជននៅច្រើនទេ?

គួន ៖ នៅ ។

ធានី ៖ ហើយគាត់ជនជាតិហើយខ្មែរយើង?

គួន ៖ ខ្មែរយើង ។

ធានី ៖ បន្ទាប់មកទៀត ដល់ភូមិ?

គួន ៖ មកធ្លាក់មកត្រពាំងតាវ ។

ធានី ៖ ត្រពាំងតាវមានប្រជាជនរស់នៅដែរ?

គួន ៖ មាន ។

ធានី ៖ អានឹងគេហៅភូមិនឹង?

គួន ៖ ភូមិ ។

ធានី ៖ ប្រជាជនចាស់នៅនឹងច្រើនទេ?

គួន ៖ នៅច្រើន ។

ធានី ៖ ជនជាតិដែរ ឬក៏?

គួន ៖ ទេ! ខ្មែរសុទ្ធ ។

ធានី ៖ ចុះដល់ពេលទៅដល់ភូមិណាទៀត?

គួន ៖ចេញពីនឹងបានធ្លាក់មកតាដេវ ។

ធានី ៖ តាដេវនឹងមានប្រជាជននៅច្រើនទេ?

គួន ៖ នៅ បាទ! ភូមិចាស់គេដែរ ។

ធានី ៖ កាលនឹងនៅច្រើនៗទាំងអស់គ្នា?

គួន ៖ នៅច្រើន ។

ធានី ៖ អត់មានអីទេ?

គួន ៖ មិនជាច្រើនប៉ុន្មាន មួយភូមិៗ៣០-៤០គ្រួ(សារ) ។

ធានី ៖ គាត់ធ្វើអីគេទៅ?

គួន ៖ ធ្វើស្រែធម្មតា ។

ធានី ៖ ចុះតាដេវនឹងប្រជាជនចាស់ ហើយថ្មី?

គួន ៖ ប្រជាជនចាស់ តែសព្វថ្ងៃចំរុះហើយ ។

ធានី ៖ តែកាលមុនប្រជាជនចាស់ដែរ?

គួន ៖ បាទ!

ធានី ៖ តែអត់ដឹងថាគាត់ជនជាតិអីទេ អត់បានសួរ?

គួន ៖ ជនជាតិខ្មែរទាំងអស់ ។

ធានី ៖ បន្ទាប់មកទៀត?

គួន ៖ មកលំទង់យើង ។

ធានី ៖ ចឹងចេញពីតាដេវមកដល់លំទង?

គួន ៖ បាទ! ចេញពីតាដេវមកឆ្លងស៊ឹងបានធ្លាក់មកលំទង ។

ធានី ៖ ឆ្លងស៊ឹងអីគេលោកតា?

គួន ៖ ឆ្លងស៊ឹងអូរជីកយើង ។

ធាន់ ៖ ឆ្លងលំបាកទេ?

គួន ៖ ទេ! កាលនោះខែប្រាំងអត់មានទឹកទេ ។

ធានី ៖ អត់មានទឹកទេ ចឹងយើងឆ្លងបាន?

គួន ៖ បាទ!

ធានី ៖ ចឹងលោកតាដើរ ចាំមើលឆ្នាំ៧៥មិនលោកតាទៅដល់ បែកយើងឈប់វៃ ឈប់មានសង្គ្រាម ពេលលោកតាទៅនៅបានម៉ាខែបានមកនៅក្រឡាញ់ៗបានម៉ាខែទៀតបានទៅអន្លង់វែង?

គួន ៖ ទេ! មកសពោង ។

ធានី ៖ មកសំពោងសិន?

គួន ៖ បាទ!

ធានី ៖ មកសំរោងបានប៉ុន្មាន?

គួន ៖ មកសំរោងបានមួយអាទិត្យបានមកនៅឈើក្រំ ។

ធានី ៖ សំរោងបានមួយអាទិត្យមកនៅឈើក្រុំៗប៉ុន្មានថ្ងៃទៀត?

គួន ៖ ឈើក្រុំបានមិនយូរទេ ឈើក្រុំប្រហែលកន្លះខែរ បានបញ្ជូនដើរជើងទ័ព ។

ធានី ៖ ប៉ុន្តែលោកតាថា ឡានខះទៅអត់បានទេ?

គួន ៖ ខែវស្សាឡានអត់មករួចទេ បានខែប្រាំង ។

ធានី ៖ តែពេលលោកតាមកដល់អន្លង់វែងនេះ មកដល់?

គួន ៖ មកថ្មើរជើង មកដល់នេះខ្ញុំបើកផ្លូវមុនគេជាមួយប្រជាជនឡានកាលនោះ កាលវានៅខែវស្សាយើងនេះ ។

ធានី ៖ តែឡានមកអត់កើត?

គួន ៖ បាទ! មកបាន មកតិចៗ ។

ធានី ៖ មកតិចៗមកសម្រាក?

គួន ៖ បាទ!

ធានី ៖ ជិះឡានអីគេកាលនឹង?

គួន ៖ សេអ៊ីមសេ ។

ធានី ៖ ទាំងពីរឡាន?

គួន ៖ បាទ!

ធានី ៖ មានអាត្រាក់មួយនាំផ្លូវ?

គួន ៖ អាត្រាក់មួយគ្រឿង ។

ធានី ៖ ហើយចឹងមកដល់លំទងនេះ មកកន្លែងលោកតានៅរាល់ថ្ងៃ ឬក៏ទៅដល់កន្លែងណា លំទង?

គួន ៖ ទៅនៅទៅអន្លង់វែងទៅ ។

ធានី ៖ លំទងហើយមកដល់អន្លងវែង?

គួន ៖ បាទ! ទៅបន្ទាយត្រង់ស៊ីសខាងកើតអន្លង់វែង ខាងកើតវត្ត ។

ធានី ៖ ខាងកើតវត្តអន្លង់វែង?

គួន ៖ ត្រង់ផ្ទះនេះទៅឃើញខាងជើងថ្នល់ ហៅបន្ទាយត្រង់ស៊ីស បន្ទាយធំគេពីដើម ។

ធានី ៖ តែនឹងផ្ទះរបស់អ្នកនាគេ?

គួន ៖ ផ្ទះតានេះដែលគេចាប់ តា ម៉ៅ ។

ធានី ៖ ផ្ទះ តា ម៉ៅ?

គួន ៖ បាទ!

ធានី ៖ ចឹងពេលលោកតាមកដល់លំទងយើងសម្រាកអត់?

គួន ៖ សម្រាក ។

ធានី ៖ តែមកដល់លំទងនឹង ភូមិលំទងចាស់នឹង?

គួន ៖ បាទ! លំទងចាស់ ។

ធានី ៖ យើងទៅដល់លំទងចាស់នឹងសិន ហើយបានយើងដើរមករហូតមកដល់ អន្លង់វែង?

គួន ៖ បាទ!

ធានី ៖ មកដល់អន្លង់វែង លោកតាស្នាក់នៅបន្ទាយត្រង់ស៊ីស?

គួន ៖ បាទ!

ធានី ៖ ហើយបន្ទាយនឹងយូរហើយ?

គួន ៖ បន្ទាយតាំងពីសង្គម ។

ធានី ៖ របស់អ្នកណាគេ?

គួន ៖ បន្ទាយនឹងអត់ដឹងដែរ បន្ទាយទាហាន លន់ នល់ ពីដើម ដែលគេរំដោះបានទៅខ្លះរត់ឡើងទៅថៃ ទាហាន ខ្លះទុកនៅនឹងភូមិចេក ដាប់ដីដែកគេរើចោលអស់ដឹង ឃើញតែប្រពន្ធដែលខ្ញុំមកនឹង ។

ធានី ៖ នៅភូមិរំចេកនឹង?

គួន ៖ បាទ!

ធានី ៖ ភូមិរំចេកនៅអន្លង់វែងយើង?

គួន ៖ រំចេកនៅព្រៃស្អាកយើង ។

ធានី ៖ ដល់ពេលលោកតាមកដល់តាមផ្លូវម៉េចដែរ ប្រជាជនសប្បាយចិត្តទេ ពេលឃើញទ័ពអីចឹង?

គួន ៖ ទេ! អត់អីទេ តាមខ្ញុំមក អ្នកភូមិនេះ បាយមិនអត់ទេ ពីដើមមិញ ដែលខ្ញុំមកអត់ទាន់ខ្លាំងទេ សហករណ៍គេនៅមិនទាន់រៀបចំសហករណ៍ស្រួលបួល ។

ធានី ៖ អត់ទាន់រៀបទេ?

គួន ៖ បាទ! ខ្ញុំនៅបានមួយឆ្នាំបានគេរៀបចំសហករណ៍ស្រួលបួល ។

ធានី ៖ ចឹងលោកតាមកខែប្រាំងត្រូវទេ?

គួន ៖ បាទ! ខ្ញុំមកខែវស្សា ។

ធានី ៖ មិននៅខែវស្សាដល់ប៉ុន្មាន?

គួន ៖ ខ្ញុំមកខែវស្សាពីដើម ។

ធានី ៖ មកអន្លង់វែងនៅបន្ទាយត្រង់ស៊ីស?

គួន ៖ បាទ!

ធានី ៖ ហើយបើយើងគិតពីឥឡូវបន្ទាយនឹងវាអាចនៅខាងណាណាសាលាស្រុក?

គួន ៖ នៅខាងជើងថ្នល់ ។

ធានី ៖ នៅខាងជើងថ្នល់?

គួន ៖ បាទ! នៅកើតចុងកើត ។

ធានី ៖ ឆ្ងាយពីអូរជីក?

គួន ៖ ខាងនោះសាលាថ្មី ខាងកើតសាលាថ្មី ខាងជើងថ្នល់ ។

ធានី ៖ ឆ្ងាយដែរ?

គួន ៖ បាទ! ឆ្ងាយ ។

ធានី ៖ ហើយស្នាក់នៅនឹងរហូត?

គួន ៖ ស្នាក់នៅនឹងរហូតបានបែកគ្នាទៅនៅជើងភ្នំ យកធ្វើការលើភ្នំ ។

ធានី ៖ ជាតិនឹងអ្នកចាត់ចែង?

គួន ៖ បាទ!

ធានី ៖ ជាតិនឹងចាត់ចែងលោកតាឲ្យធ្វើការលើភ្នំ?

គួន ៖ បាទ!

ធានី ៖ តែកាលនឹងយើងអត់ស្គាល់ផ្លូវចឹង យើងធ្វើម៉េចទៅដល់ទៅដល់លើភ្នំ?

គួន ៖ វាមានទ័ពស្រុកគេនៅ ទ័ពស្រុកនៅអន្លង់វែង ។

ធានី ៖ ឈ្មោះអីគេអ្នកដឹកនាំទ័ពស្រុកនឹង?

គួន ៖ ភ្លេចឈ្មោះគណៈស្រុកគេ ឈ្មោះអីទេខ្ញុំភ្លេចទៅគណៈស្រុកគេរត់ឡើងទៅថៃ ។

ធានី ៖ លោកតា រកនឹកមើល គាត់ឈ្មោះអីគេ?

គួន ៖ ភ្លេចមិនដឹងអ្នកណា តា រ៉ុង ។

ធានី ៖ តា រ៉ុង គណៈស្រុកអន្លង់វែង?

គួន ៖ បាទ!

ធានី ៖ តែអន្លង់វែង កាលនឹង គឺជាស្រុក?

គួន ៖ ស្រុក ។

ធានី ៖ ស្រុកអន្លង់វែងតែម៉ង?

គួន ៖ បាទ!

ធានី ៖ ដែលមានភូមិលំទង ភូមិអីៗនឹង?

គួន ៖ បាទ!

ធានី ៖ តែអត់មានឃុំទេ?

គួន ៖ មានទេ ខ្ញុំមកអត់មានឃុំទេ ។

ធានី ៖ ប៉ុន្តែគេហៅស្រុក?

គួន ៖ បាទ! ពេលចូលឆ្នាំមកគេមកលេងនឹងវត្តអន្លង់វែង មានឃុំផ្អាវនេះ ។

ធានី ៖ ប៉ុន្តែចង់និយាយថា កាលសម័យលោកតាអញ្ជើញទៅដល់នឹង គឺគេហៅអន្លង់វែងគឺជាស្រុកហើយ?

គួន ៖ បាទ!

ធានី ៖ តែចុះស្រុកនឹងកកើតពីណាមកដឹងទេ?

គួន ៖ អត់ដឹងទេ ។

ធានី ៖ ដឹងថា?

គួន ៖ មកឃើញគណៈស្រុកគេ តា រ៉ុងនឹង ។

ធានី ៖ គេហៅគណៈស្រុក តា រ៉ុង?

គួន ៖ បាទ!

ធានី ៖ កាចទេ គាត់នឹង?

គួន ៖ ទេ! មិនជាកាច មិនជាស្លូត ។

ធានី ៖ ចុះលោកតាមញថាគាត់អញ្ជើយទៅថៃ?

គួន ៖ បាទ! គេរត់ទៅ ។

ធានី ៖ ម៉េចចឹង?

គួន ៖ ដឹង ខ្លាចគេយកទៅវៃចោល ។

ធានី ៖ ឆ្នាំប៉ុន្មានគេរត់ទៅ តា រ៉ុង នឹង?

គួន ៖ ៧៦ ។

ធានី ៖ ១៩៧៦ រត់ទៅថៃ ។ ម៉េចចឹងលោកតា?

គួន ៖ អត់ដឹងដែរ ។

ធានី ៖ ហើយចុះដល់ពេលគាត់រត់ទៅ អ្នកណាគេមកជំនួសគាត់ទៅ?

គួន : អត់ទេ វានៅធម្មតា ។

ធានី : លែងមានគណៈស្រុកហើយ?

គួន : បាទ!

ធានី : ចឹងបានអ្នកណាគ្រប់គ្រង?

គួន : នៅមានតែទាហាន ។

ធានី : ទាហានអ្នកគ្រប់គ្រង?

គួន : ហើយប្រជាជនគេជម្លៀសទៅនោះ ទៅក្រឡាញ់-កំពង់ថ្កូវវិញ ។

ធានី : ចឹងលោកតាមកពីកំពង់ថ្កូវ-ក្រឡាញ់ ឥឡូវទៅឲ្យប្រជាជនអ្នកទៅវិញ?

គួន : បាទ!

ធាន់ : ចឹងគេដូរគ្នា?

គួន : ប្រជាជនជម្លៀសនិយាយរួម ផ្អាវ បុស្សី អន្លង់វែង គេជម្លៀសទៅក្រឡាញ់ ។

ធានី : ម៉េចចឹងលោកតា ម៉េចបានគេជម្លៀសចេញអត់ឲ្យនៅ?

គួន : មិនដឹងម៉េច គេត្រូវជម្លៀស ។

ធានី : តែកាលដំបូងក្រែងលោកតាថាប្រជាជននៅហើយធ្វើសហករណ៍ទៀត?

គួន : ពីដើមនៅ ។

ធានី : នៅហើយធ្វើសហករណ៍ទៀត លោកតានិយាយនោះ?

គួន : បាទ! សហករណ៍ ដល់ខ្ញុំមកនៅបានម៉ាឆ្នាំ២ឆ្នាំ បានគេជម្លៀសប្រជាជនចេញ ។

ធានី : ចឹងកាលឆ្នាំ៧៦នឹង ពេលដែល តា រ៉ុង រត់ទៅថៃ ទ័ពយើងនឹងអ្នកគ្រប់គ្រងអស់នឹងដែរ ធម្មតា ធ្វើសហករណ៍ដដែល?

គួន : បាទ! ជម្លៀសប្រជាជនទាំងអស់ ។

ធានី : តែអត់ទាន់ជម្លៀសទេ?

គួន : ជម្លៀស ។

ធានី : លោកតាថានៅ២ឆ្នាំ បានជម្លៀសបានជម្លៀស?

គួន : បាទ!

ធានី : ព្រោះអីឆ្នាំ៧៥ លោកតាមកដល់?

គួន : បាទ!

ធានី : ដល់ពេល៧៦ តា រ៉ុង រត់បាត់?

គួន : ហ្នឹង ។

ធានី :	ចឹងចន្លោះពី៧៦ អាចថា៧៧បានចាប់ផ្ដើមជម្លៀស?

គួន :	៧៧ ។

ធានី :	ចឹង តា វ៉ុង រស់នៅនឹងដល់៧៦ គាត់រត់ទៅបាត់ ហើយខាងទ័ពយើងអ្នកណាគេអ្នកគ្រប់គ្រងនៅនឹង?

គួន :	តា ជាតិ ។

ធានី :	តា ជាតិ នឹងដឹកនាំតែមួយវរសេនាតូចទេមកភូមិយើងនឹង?

គួន :	បាទ! មួយវរសេនាតូច ។

ធានី :	ចុះមកដល់នេះ គេកកើតជាកងពល ឬក៏វរសេនាធំអីដែរអត់?

គួន :	នៅតែដដែល ។

ធានី :	នៅវរសេនាតូចដដែល?

គួន :	អឺ!

ធានី :	វរសេនាតូចមានគ្នាប៉ុន្មាននាក់?

គួន :	៥០០ ។

ធានី :	៥០០នាក់ គាត់យកពីនោះមក?

គួន :	បាទ! យកពីក្នុងមក ។

ធានី :	ចឹងលោកតាអញ្ជើញទៅជាមួយគាត់៥០០នាក់ មកអន្លង់វែងនេះ?

គួន :	បាទ!

ធានី :	ហើយទ័ពស្រុកនៅនឹងមានប៉ុន្មាននាក់ទៅ?

គួន :	ទ័ពស្រុកមានប៉ុន្មាន ទ័ពស្រុកតិច ហ៎! មិនដល់១០០ ៥០នាក់ ។

ធានី :	ចុះអ្នកណាគេអ្នកក្ដាប់ទ័ពស្រុកនឹងទៅ?

គួន :	នៅ តា ម៉ឺន នៅលំទង ។

ធានី :	តា ម៉ឺន គាត់នៅលំទងរាល់ថ្ងៃ?

គួន :	បាទ!

ធានី :	តា មន ឈ្មោះអីគេ មន?

គួន :	ទេ! ខ្ញុំអត់ស្គាល់ ។

ធានី :	តែរាល់ថ្ងៃគាត់រស់នៅលំទង?

គួន :	នៅរស់ ។

ធានី :	នៅលំទងចាស់?

គួន ៖ បាទ!

ផានី ៖ គាត់ធ្វើការអីដែររាល់ថ្ងៃ?

គួន ៖ អត់ទេ ធ្វើស្រែធម្មតា ។

ផានី ៖ ប្រពន្ធគាត់ឈ្មោះអីគេទៅ?

គួន ៖ ឈ្មោះ សៀ ប៉ុនមិនដឹងស្តី សៀ ។

ផានី ៖ តា ម៉ឺន នឹងកាលមុនជាគណៈយោធា ទ័ពស្រុកៗ?

គួន ៖ បាទ!

ផានី ៖ ប្រធានទ័ពស្រុក ។ តា មឿន តា ម៉ឺន?

គួន ៖ តា ម៉ឺនៗ ។

ផានី ៖ តា ម៉ឺន ១ម៉ឺន ២ម៉ឺន?

គួន ៖ បាទ! ហ្នឹងហើយ ។

ផានី ៖ ចឹង តា ម៉ឺន ប្រពន្ធគាត់ឈ្មោះ សៀ ហើយរាល់ថ្ងៃគាត់រស់នៅលំទងចាស់ ហើយគាត់កាលមុនជាគណៈទ័ពស្រុក?

គួន ៖ អឺ! នៅក្រោមបទបញ្ជាគេ ចេះតែធ្វើទៅ ។

ផានី ៖ ប៉ុន្តែលោកតាបានស្គាល់គាត់ដែរ?

គួន ៖ បាទ!

ផានី ៖ គាត់ស្គាល់លោកតា?

គួន ៖ ស្គាល់ ។

ផានី ៖ ហើយដូចលោកតាមានផាររអីគេដែរ បានគាត់ស្គាល់កាលនឹង?

គួន ៖ ទេ! ស្គាល់គ្នា យើងមកទាក់ទងគេស្រុកទៅ ឲ្យគេជូនធ្វើការលើភ្នំ ។

ផានី ៖ ចឹងតា ម៉ឺន នឹងអ្នកចាត់ចែងជូនលោកតា ។ លោកតាកាលនឹងមានផាររជាអីដែរ បានគេ?

គួន ៖ ខ្ញុំអត់មានអីទេ របួត លុះសព្វថ្ងៃ ។

ផានី ៖ ចាំ?

គួន ៖ របួតទល់ចប់ ។

ផានី ៖ អត់មានផាររអីនឹងគេ ព្រោះយើងតស៊ូយូរហើយ?

គួន ៖ អត់ចង់បាន ។

ផានី ៖ អត់ដែរ គេឲ្យដែរ?

គួន ៖ ឲ្យដែរ ។

ធានី : កាលនឹងគេឲ្យធ្វើអីគេ?

កូន : ឲ្យធ្វើកងធំ ប៉ុនខ្ញុំអត់។

ធានី : កងធំគ្រប់គ្រងប៉ុន្មាននាក់នាក់បើសិនលោកតាធ្វើ?

កូន : ១០០។

ធានី : ១០០នាក់ អ្នកណាគេអ្នកឲ្យលោកតាឡើងធ្វើកងធំ?

កូន : ជាតិ។

ធានី : ឆ្នាំប៉ុន្មានកាលនឹងលោកតា?

កូន : ៧៦។

ធានី : ប៉ុន្តែលោកតាបដិសេធ?

កូន : បាទ!

ធានី : ហេតុអីបានលោកតា បដិសេធចឹង?

កូន : ខ្ញុំអត់ធ្វើ ព្រោះម៉ែឪខ្ញុំគាត់ធ្លាប់តែយាមនង្គ័ល។

ធានី : ដោយសារលោកតា ធ្វើស្រែ អត់ចង់ធ្វើធំ?

កូន : បាទ! អត់ចង់ធ្វើទាហានទេ។

ធានី : អត់ចង់ធ្វើទាហាន ប៉ុន្តែយើងធ្វើទាហានដដែល ម៉េចអត់ចង់ធ្វើធំ?

កូន : បាទ! អត់ចង់។ យើងធ្វើដោយគេបង្ខំ។

ធានី : មិនចង់ធ្វើទាហាន តែធ្វើទាហាននៅតែធ្វើដដែល ប៉ុន្តែអត់ចង់ធ្វើធំ?

កូន : បាទ!

ធានី : ចឹង តា ជាតិ ឲ្យអ្នកណាគេជំនួសទៅ?

កូន : ឲ្យគេអ្នកជំនួស។

ធានី : ឲ្យឈ្មោះអីគេ?

កូន : ឲ្យទៅអា អូ។

ធានី : ឈ្មោះ អូ?

កូន : បាទ!

ធានី : គាត់មកពីណាដែរ?

កូន : មកពីដីក្រែង។

ធានី : ចឹង អូ នឹងជាប្រធានជំនួសលោកតាវិញ?

កូន : បាទ!

ធានី ៖ ហើយលោកតាធ្វើជាទាហាននៅក្រោម អ៊ូ នឹង?

គួន ៖ បាទ! ខ្ញុំនៅយុទ្ធជន។

ធានី ៖ ឈ្មោះ អ៊ូ ចឹង?

គួន ៖ បាទ!

ធានី ៖ អ៊ូរយើង អ៊ូរទឹក?

គួន ៖ បាទ!

ធានី ៖ អត់ដឹងត្រកូលគាត់ឈ្មោះអី?

គួន ៖ អត់ដឹងទេ។

ធានី ៖ ហើយ អ៊ូរ នឹង គាត់អ្នកធ្វើជាប្រធានកងធំ?

គួន ៖ បាទ!

ធានី ៖ ចុប្រធានក្រុម ប្រធានអីរបស់លោកតា ឈ្មោះអីដែរ?

គួន ៖ ដែលចាំបានអស់ទេ បែកគ្នា។

ធានី ៖ ចាំតែអ៊ូរនឹង?

គួន ៖ បាទ! ប្រធានកងធំ។

ធានី ៖ ហើយបន្ទាប់មកទៀត ពេលនឹងគេចាត់ឲ្យលោកតាទៅណា នៅពេលដែល មិញលោកតា ថាទៅដល់អន្លង់វែងភ្លាម មិនអាចទៅណាភ្លាមទេ ដោយសារ?

គួន ៖ ទៅលើខ្នងភ្នំ។

ធានី ៖ អត់ទេ ចង់និយាយថា មានសម្រាកអីទៀតអត់ទេ នៅពេល?

គួន ៖ បាទ! សម្រាកនៅបន្ទាយត្រង់ស៊ីស។

ធានី ៖ សម្រាកប្រហែលប៉ុន្មានខែ បានគេចាប់ផ្ដើមបញ្ជូនឲ្យ?

គួន ៖ ចែកមុខការគ្នាធ្វើលើភ្នំ។

ធានី ៖ ប៉ុន្តែចង់ថា សម្រាកនឹងបានប៉ុន្មានខែ បានគេចែកមុខការគ្នាធ្វើ?

គួន ៖ អត់ដល់មួយខែទេ តែមួយអាទិត្យ។

ធានី ៖ រយះពេលមួយអាទិត្យ?

គួន ៖ បាទ! ចែកគ្នាដើរធ្វើការលើភ្នំ។

ធានី ៖ តែពេលលោកតាមកតាមផ្លូវ មានព្រៃច្រើនទេ?

គួន ៖ ព្រៃទេរ។

ធានី ៖ ព្រៃទេរម៉េច?

គួន ៖ បាទ! ព្រៃដីរ ព្រៃខ្លា ។

ធានី ៖ ហើយអ្នកភូមិនៅនឹងទាំងក្នុងព្រៃម៉ង?

គួន ៖ បាទ! ភូមិនេះឯង ។

ធានី ៖ ហើយគាត់បេះនៅកើតដែរ?

គួន ៖ នៅតែចុះ គាត់ធ្លាប់ ។

ធានី ៖ ចុះលោកតាខ្លាចទេ?

គួន ៖ ខ្លាច ប៉ុនកាំភ្លើងនឹងដៃ ខែវស្សាឡើងដីរវា ដីរទាំងហ្វូង ។

ធានី ៖ ចុះនៅអន្លង់វែងយើងព្រៃដែរ?

គួន ៖ ព្រៃ អាផ្លូវចុះទៅអូរជីកនឹង ខែវស្សាឡើងសត្វវាមកនៅអាកូនភ្នំ ខាងនេះអាជិតផ្លូវចុះទៅ

ធានី ៖ ចុះកន្លែងផ្ទះ តា ម៉ុក កាលមុនកូនភ្នំ?

គួន ៖ អានោះកូនភ្នំ មិនដែលមានអ្នកណាហ៊ានចូលទេ ។

ធានី ៖ ម៉េចចឹង?

គួន ៖ ពស់ៗច្រើនកាលនឹង ។

ធានី ៖ ពស់អីខ្លះទៅ?

គួន ៖ ពស់វែកក្របី វែករនាម ។

ធានី ៖ នៅលើកូនភនឹង?

គួន ៖ បាទ! មានតាំងពី ខ្លា ។

ធានី ៖ នៅលើកូនភ្នំនឹង?

គួន ៖ បាទ!

ធានី ៖ យើងមើលឃើញដែរ?

គួន ៖ ទេ! ព្រៃធំចឹងមិនហ៊ានរុកទេ គ្រាន់តែឃើញគ្រលង ។

ធានី ៖ ព្រៃធំ ចឹងនៅអន្លង់វែងយើងព្រៃ?

គួន ៖ ព្រៃទេរ ខាងជើងមាត់ស្ទឹង ខាងនេះមាត់ស្ទឹងព្រៃ ។

ធានី ៖ ចុះនៅកន្លែងលោកតាស្នាក់នៅព្រៃដែរ?

គួន ៖ ព្រៃជុំវិញ ប៉ុនមានផ្ទះ មានរោងគេនៅបន្ទាយទាហាន ។

ធានី ៖ ចុះនៅអន្លង់វែងយើងនឹងមានទីស្នាក់ការគណៈស្រុកអីនៅនឹងដែរ?

គួន ៖ បាទ!

ធានី ៖ ហើយមានប្រជាជនយើងរស់នៅទេ?

គួន ៖ នៅ ទើបនឹងចប់វៃគ្នាចប់ទៅ ជំនាន់យួនចូលមក បានប្រជាជនរត់ពីក្រឡាញ់មកនៅ ។

ធានី ៖ តែកាលមុន ពេលដែលលោកតាទៅដល់ដំបូងនឹងមានប្រជាជនរត់នៅទេ?

គួន ៖ នៅៗច្រើន ។

ធានី ៖ ប្រជាជននៅហើយធ្វើសហករណ៍ដែរ?

គួន ៖ បាទ!

ធានី ៖ លោកតាបានដឹងថា ប្រធានសហករណ៍នៅអន្លង់វែងនឹងឈ្មោះអី?

គួន ៖ ប្រធានសហករណ៍គេឈ្មោះអីត្រង់ណាទេ ប្រធានសហករណ៍ ស្លាប់ហើយ ។

ធានី ៖ គាត់ឈ្មោះអីគេទៅលោកតា?

គួន ៖ ឈ្មោះ សែមៗអីត្រង់ណាទេ ខ្ញុំភ្លេច ។

ធានី ៖ សែម ឬសែប?

គួន ៖ អ្នកក្តាប់ប្រធានសហករណ៍ អេ!កាលនោះគណៈស្រុកគេក្តាប់ប្រធានសហករណ៍គេ ។

ធានី ៖ ប៉ុន្តែចង់ដឹងថា?

គួន ៖ អាអ្នកដែលក្តាប់សហករណ៍ផ្ទាល់ប្រជាជនទេ ។

ធានី ៖ ចាំ!ហ្នឹងហើយ ប្រជាជនដែលគាត់ជាប្រធានសហករណ៍នៅអន្លង់វែងនឹងគាត់ឈ្មោះអីគេ?

គួន ៖ ដឹងត្រង់ណាទេ ភ្លេចហើយឈ្មោះប្រធានសហករណ៍ រកនឹកមិនឃើញទេ យូរណាស់បែកគ្នាយូរ ។

ធានី ៖ រកនឹកអត់ឃើញលោកតា?

គួន ៖ អត់ឃើញទេ ។

ធានី ៖ ធ្លាប់ជួបគាត់ដែរ ធ្លាប់ជជែកលេងជាមួយគាត់ដែរ?

គួន ៖ ទេ! កាលនៅប្រធានសហករណ៍ ខ្ញុំនឹងឯងដើរទៅធ្វើការឯមុខ អត់ដុយនិយាយលេង ។

ធានី ៖ កាលលោកតាមកដល់ដំបូង អត់ទាន់មានទេភូមិធម្មតា?

គួន ៖ អឺ!

ធានី ៖ បានដល់ពេលឆ្នាំប៉ុន្មាន បានចាប់ផ្តើមធ្វើសហករណ៍?

គួន ៖ ៧៥ វាមានហើយ ប៉ុនវាមិនទាន់រៀបចំជាសហករណ៍អីស្រួលបួល ។

ធានី ៖ ដល់ពេលណាបានគេរៀបស្រួលបួល?

គួន ៖ ខ្ញុំមកនៅបាន២ឆ្នាំ បានគេរៀបចំសហករណ៍ ៧៦ ។

ធានី ៖ ៧៦គេរៀបសហករណ៍?

គួន ៖ បាទ!

ធានី ៖ ចឹង ពេល តា រ៉ុង នឹងគាត់នៅបានប៉ុន្មានខែ ទើបបានគេសហករណ៍?

គួន ៖ តា រ៉ុង នឹងបានឡើងមកមុនៗខ្ញុំ ។

ធានី ៖ ចឹង តា រ៉ុង គាត់ចាប់ផ្ដើមរៀបចំសហករណ៍ទៅ?

គួន ៖ បាទ! សហករណ៍ ។

ធានី ៖ តែ តា រ៉ុង នឹងគាត់គ្រប់គ្រងនៅនឹងយូរហើយ?

គួន ៖ និយាយរួម តា រ៉ុង មកដល់តាំងពីទាហាន ចបសង្រ្គាមលន់ នល់ទៅមកដល់ ។

ធានី ៖ ឆ្នាំប៉ុន្មានទៅលោកតា ព្រោះអីធម្មតាយើងនៅតាមភូមិនេះ កន្លែងខ្លះរំដោះហើយ គេហៅតំបន់រំដោះ?

គួន ៖ បាទ!

ធានី ៖ តែលោកតា ដឹងទេ តា រ៉ុង គាត់មកតាំងពីពេលរំដោះនឹងពីឆ្នាំណា?

គួន ៖ តា រ៉ុង មកពី៧៥ ។

ធានី ៖ ៧៥ដែរ?

គួន ៖ បាទ!

ធានី ៖ មុនលោកតា?

គួន ៖ មុន ។

ធានី ៖ តែលោកតាមក៧៥ដែរ តែចុង?

គួន ៖ បាទ! ចុង ។

ធានី ៖ តា រ៉ុង នៅដើមឆ្នាំ?

គួន ៖ បាទ!

ធានី ៖ ចឹងខាងកន្លែងយើងនេះសមរភូមិក្ដៅដែរ?

គួន ៖ សមរភូមិក្ដៅ ។

ធានី ៖ អន្លង់វែង ទម្រាំរំដោះបាន?

គួន ៖ បាទ!

ធានី ៖ យូរដោងអ្នកនៅខាងក្នុង ខាងតំបន់លោកតា?

គួន ៖ យូរ ។

ធានី ៖ យូរដោង?

គួន ៖ បាទ! បើយើងវ៉ៃខ្លាំងទៅទាហានគេរត់ទៅថៃ ។

ធានី ៖ ចុះយើងវ៉ៃបែកគឺទាហានគេរត់ទៅថៃអស់ហើយ យើងដែលចាប់បានទេ?

គួន :	បាន ហេ៎! អាខ្ទះ ។

ធានី :	ពេលលោកតាមកដល់នឹងនៅវៃទៀតអត់?

គួន :	ទេ! ខ្ញុំមកដល់ គេវៃរួចអស់ហើយ ។

ធានី :	គេសម្រេចហើយ?

គួន :	បាទ!

ធានី :	ប៉ុន្តែ តា រ៉ុង អ្នកដឹកនាំវៃ?

គួន :	បាទ!

ធានី :	ចឹងពេលដែលលោកតាមក តា រ៉ុង អ្នកគ្រប់គ្រងហើយ ។ ហើយ តា រ៉ុង នឹងជាអ្នកចាត់ចែងឲ្យ ជាតិ នឹងដឹកនាំលោកតា ឡើងលើភ្នំ?

គួន :	ហ្នឹង!

ធានី :	ហើយឡើងលើភ្នំនឹងឡើងម៉េចទៅ ឡើងតាមណា?

គួន :	ឡើងតាមផ្លូវគេ ។

ធានី :	មានផ្លូវដើរគេដែរ?

គួន :	មានផ្លូវគេ អ្នកភូមិនេះគេរៀបប្រហុករៀបអីឡើងទៅលក់ឲ្យថៃនឹង ផ្លូវខ្សែលួសគេនឹង ។

ធានី :	ផ្លូវខ្សែលួស ផ្លូវនឹងផ្លូវយ៉ាងម៉េចទៅ?

គួន :	ផ្លូវវាចំណោទៗ ដើរឡើងរាយពេញតែនឹង ។

ធានី :	អត់ទាន់មានផ្លូវដូចយើងរាល់ថ្ងៃ?

គួន :	អត់ទេ! ផ្លូវនោះដុះព្រៃ ឡើងគោងឈើ គោងវល្លិ៍ឡើង ។

ធានី :	ហើយលោកតាឡើង?

គួន :	ឡើង ។

ធានី :	ដែលធ្លាប់ដើរព្រៃពីមុនមកទេ?

គួន :	ដើរ ។

ធានី :	ធ្លាប់ដែរ?

គួន :	បាទ!

ធានី :	តែវាដូចថានៅនឹងព្រៃច្រើនចឹង ដូចថាមានជម្ងឺមានអីច្រើនទេ?

គួន :	ទេ! អត់សូវអីទេ ធម្មតា ។

ធានី :	អត់សូវចាញ់ទេ?

គួន :	ប៉ុនតំបន់នេះគេថាចាញ់ខ្លាំង ប៉ុនថាធម្មតាពួកខ្ញុំផាប់អស់៤៨ មួយវរសេនាតូច ។

ផានី ៖ មួយវរសេនាតូចលោកតា?

គួន ៖ បាទ! គ្រុនចាញ់ ហើយស្លាប់នឹងត្រូវមីនផង ។

ផានី ៖ មានមីនដែរ?

គួន ៖ មីន ។

ផានី ៖ តាំងពី៧៥នឹង?

គួន ៖ បាទ!

ផានី ៖ ហើយចឹងធ្វើម៉េចទៅ បើស្លាប់ច្រើនចឹង បានទ័ពពីណាមកជួសទៅ?

គួន ៖ ទេអត់មានជួសទេ ស្លាប់ប៉ុនណានៅប៉ុននឹង ។

ផានី ៖ ចឹងតាំងពី៥០០នាក់ នៅសល់ប៉ុន្មានទៅ?

គួន ៖ អស់នៅ៤០ នៅ៤០នាក់ ៥០០ ។

ផានី ៖ តែក្នុងវរៈរបស់លោកតានឹង គឺអស់៤០?

គួន ៖ បាទ! អស់៤០ ។

ផានី ៖ ដឹងវរផ្សេងៗដឹងអស់ប៉ុន្មានទៀត?

គួន ៖ បាទ! នេះគ្រុនចាញ់ ។

ផានី ៖ គេមានឲ្យថ្នាំ?

គួន ៖ មានពេទ្យគេនៅ ពេទ្យនៅអន្លង់វែង ប៉ុនមើលអត់ទាន់ បើថាទៅធ្វើការលើភ្នំបើឃើញ ឈឺក្បាល ឆាប់បញ្ជូនមកក្រោយ ។ រៀងឈឺក្បាលហើយឆាប់បញ្ជូនមក កុំទុក ។

ផានី ៖ លោកតាធ្លាប់?

គួន ៖ ខ្ញុំគ្រុនចាញ់ ខ្ញុំទៅដេកក្រឡាញ់-កំពង់ថ្កូវ៦ខែ ។

ផានី ៖ ពីអង្កាល់ដែរ ពេលមកនឹង?

គួន ៖ បាទ! មុនមកនៅនេះបានមួយឆ្នាំ បានខ្ញុំគ្រុនចាញ់ ។

ផានី ៖ ចឹងកាល៧៦ពេល តា រ៉ុង រត់?

គួន ៖ បាទ! ៧៦បញ្ជូនទៅ ។

ផានី ៖ ៦ខែ ហើយបានត្រឡប់ទៅវិញ?

គួន ៖ បាទ!

ផានី ៖ ចឹងកាលនឹងលោកតាមកដល់ភូមទៅណាមុនគេ?

គួន ៖ អត់មានទៅណាទេ ទៅលើភ្នំនឹង ។

ផានី ៖ លើភ្នំនឹងខាងណា មានច្រើនច្រក ទិស?

គួន ៖ នេះប្រកអន្លង់វែងយើង ។

ធានី ៖ លោកតា ទៅខាងប្រកជានឹង?

គួន ៖ បាទ!

ធានី ៖ ឡើងតាមប្រកនឹង ឡើងទៅលើទៅ?

គួន ៖ វាបែកមុខសញ្ញាគ្នាទៅ ខាងផ្លាំរមាស ខាងត្រពាំងតាវ ។

ធានី ៖ ទៅខាងណាទៀតទៅ?

គួន ៖ បែកទៅខាងបែកអន្លង់ ។

ធានី ៖ បែកអន្លង់?

គួន ៖ ទៅអូរៗ គេហៅអូរស្វាយៗ ។

ធានី ៖ ដល់លោកតានៅខាងណាទិស?

គួន ៖ ខ្ញុំនៅមុខអន្លង់វែងចំ ។

ធានី ៖ យើងនៅតំបន់អន្លង់វែងម៉ង ឬក៏យើងឡើងលើភ្នំ ប៉ុន្តែមុខអន្លង់វែង?

គួន ៖ មុខអន្លង់វែង ប៉ុន្តែធ្វើការលើខ្នងភ្នំ ។

ធានី ៖ លើខ្នងភ្នំ?

គួន ៖ បាទ! ធ្វើការដល់ឡាក់យើងពីដើមមិញ ។

ធានី ៖ ដល់ឡាក់ៗ?

គួន ៖ ឡាក់នៅទឹកខៀវ ។

ធានី ៖ ចឹងយើងនៅប្រចាំការណ៍នៅតាមឡាក់នឹង?

គួន ៖ បាទ! នៅបុសស្បូវ ទឹកខៀវ ។

ធានី ៖ ចឹងលោកតានៅឡាក់ទីប៉ុន្មានដែរ មានឈ្មោះឡាក់វា?

គួន ៖ ទេ! ខ្ញុំមិនបានមើលលេខគាលនោះ ។

ធានី ៖ ហើយប៉ុន្មាននាក់ម៉ាឡាក់ៗ?

គួន ៖ ៣០នាក់ ។

ធានី ៖ ៣០នាក់ម៉ាឡាក់?

គួន ៖ បាទ!

ធានី ៖ ហើយបែកគ្នាម្នាក់មួយម៉ែត្រទៅ?

គួន ៖ ទេ! យើងគ្រាន់ដើរធ្វើការ ឧបមាថា ថ្ងៃនេះដើរធ្វើការ១០នាក់ទៅ ល្ងាចឡើងមកវិញ មក ដាំបាយស៊ីទៅ ។

ធានី ៖ ឡើងទាន់ដែរលោកតា ឡើងទៅលើ?

គួន ៖ ទេ! ទៅដេកនៅលើខ្នង ។

ធានី ៖ នៅលើខ្នងភ្នំទេ?

គួន ៖ បាទ! យើងទៅពីខ្នងទៅឡាក់ ដីប្រហែល៣គីឡូ ទៅទន្ទឹងនឹងភូមិស្រែប្រិយ៍គេ ។

ធានី ៖ ជាប់នឹងស្រែប្រិយ៍របស់ថៃនឹង?

គួន ៖ បាទ!

ធានី ៖ ថៃនៅភូមិខាងនឹង មានប្រជាជននៅ?

គួន ៖ នៅ ។

ធានី ៖ ហើយមានទ័ពគេនៅ?

គួន ៖ ប៉ុនមិនជាប់ប៉ុន្មានទេ ដាច់គ្នាម៉ាគីឡូ ។

ធានី ៖ តែយើងនៅតាមឡាក់នឹងយើងអត់ហ៊ានចូលដីគេដែរ?

គួន ៖ អត់ទេ ។

ធានី ៖ ម៉េចចឹង?

គួន ៖ យើងគ្រាន់តែធ្វើការត្រឹមនោះ ។

ធានី ៖ ត្រឹមនឹង អត់ហ៊ានចូលដែរ?

គួន ៖ អត់ ។

ធានី ៖ ហើយឡាក់នឹងថ្មយ៉ាងម៉េចទៅ?

គួន ៖ ឡាក់ថ្មធំ ។

ធានី ៖ វាមានដាក់អីគេ?

គួន ៖ មានធ្វើដូចយើងធ្វើ គេហៅថ្មសីម៉ា ។

ធានី ៖ មានរូបយ៉ាងម៉េច?

គួន ៖ អត់មានរូបទេ ។

ធានី ៖ អត់មានរូបទេ?

គួន ៖ បាទ!

ធានី ៖ ថ្មធំសុទ្ធ?

គួន ៖ ថ្មប្អូនជ្រុង ។

ធានី ៖ ហើយគេមានសរសេរថាលេខប៉ុន្មាន ឬក៏ឡាក់ប៉ុន្មាន?

គួន ៖ មិនបានមើលលេខផង ។

ធានី ៖ គេមានសរសេរដែរ?

គួន ៖ បាទ!

ធានី ៖ ហើយគេមានថាអានឹងថ្មព្រំដែនអីចឹង?

គួន ៖ បាទ! ដាក់ថាព្រំដែន ។

ធានី ៖ ឲ្យតែឃើញថ្មនឹង ទំហំប្រហែលប៉ុន្មាន?

គួន ៖ ១ម៉ែត្រ ។

ធានី ៖ ១ម៉ែត្របួនជ្រុង?

គួន ៖ ហ៎! វៀងត្រប៉ែត ។

ធានី ៖ ទទឹងបណ្តោយវាមួយម៉ែត្រ?

គួន ៖ បាទ! ប៉ុននេះ ។

ធានី ៖ ហើយដល់ពេលលោកតានៅប៉ុន្មានខែឡើងចុះលើភ្នំម្តង?

គួន ៖ មួយខែផ្លាស់គ្នា ។

ធានី ៖ ហើយដូចថាលោកតាចុះមកម្តងៗ ឃើញអន្លង់វែងម៉េចដែរ អាចជួយពិពណ៌នាតិចបានទេ ថាអន្លង់វែងនៅតំបន់អន្លង់វែងយើងកាលពីមុនវាយ៉ាងម៉េច ពេលដែលលោកតាមកដល់ដំបូង លោកតាឃើញយ៉ាងម៉េចខ្លះ ហើយមានការចាប់អារម្មណ៍អីខ្លះចំពោះអន្លង់វែង?

គួន ៖ ហ៎! អត់មានអីចាប់អារម្មណ៍ប៉ុន្មានទេ ឃើញតែប្រជាជនលំបាក ។

ធានី ៖ ប្រជាជនលំបាក?

គួន ៖ បាទ!

ធានី ៖ លំបាកយ៉ាងម៉េចខ្លះ?

គួន ៖ លំបាកអារឿង ប៉ុនប្រជាជនលំបាកប៉ុននៅក្នុងមានហូបគ្រប់ សហករណ៍ប៉ុនសំបូរសាច់ ។

ធានី ៖ ម៉េចទៅអ៊ំពេលទៅដល់ឃើញអន្លង់វែងដំបូង?

គួន ៖ ទេ! មកដល់ឃើញប្រជាជនអ៊ូរអរដែរ ប៉ុនវាមិនដូចយើងនៅក្នុងគ្នាច្រើន ឧបមាថាក្នុងម៉ា ចំណោមគេមានអន្លង់វែងមានភូមិមួយដាច់ឡែកទៅ ប្រជាជនគេមាននៅក្រោយគ្រាន់ដែរ ផ្ទះ មានផ្លូវ៣ផ្លូវ ភូមិអន្លង់វែងនេះ ។

ធានី ៖ អូ! មានផ្លូវ៣ជរទៀត?

គួន ៖ បាទ! អាផ្លូវកណ្តាល អាផ្លូវស្រុកយើងនេះមួយ អាផ្លូវក្រោយនេះផ្លូវខាងជើងនេះមួយទៀត ។

ធានី ៖ តែអត់មានផ្លូវទៅឆ្លងស្ពានអូរជីកទេ?

គួន ៖ អត់ទេ មានផ្លូវទេះ ខាងជើងធម្មតាគេហៅថ្នល់បារាំង។ ។

ធានី ៖ គេហៅថ្នល់បារាំង ចឹងមានតាំងពីសម័យបារាំងមក?

គួន ៖ បាទ!

ធានី ៖ គេហៅថ្នល់បារាំង?

គួន ៖ បាទ!

ធានី ៖ តែថ្នល់នឹងថ្នល់នឹងថ្នល់ដីយើងធម្មតាទេ?

គួន ៖ ថ្នល់បារាំងគ្រួសក្រហម ប៉ុនវារាប។ នៅសព្វថ្ងៃ ផ្លូវទៅភូមិយាយវ៉ាន់ ថ្នល់បារាំង។

ធានី ៖ ថ្នល់នឹងតាំងពីអើយអាយចឹងម៉ង?

គួន ៖ បាទ! អាថ្នល់ធ្លាក់ទៅអូរអង្ក្រែ។

ធានី ៖ ថ្នល់នឹងធំ?

គួន ៖ ថ្នល់ប៉ុននេះ។

ធានី ៖ តែថ្នល់ក្រហមចឹង?

គួន ៖ អឺ! តែដាច់ៗព្រៃដុះលើខ្លះ អ្នកណាក៏ឃើញថ្នល់ ធ្លាក់ទៅដល់ត្រពាំងតាវ ធ្លាក់ទៅដល់ ពូអុង ថ្នល់បារាំង។

ធានី ៖ តា អុង?

គួន ៖ ពូអុង ស្នាច់។

ធានី ៖ ពូអុង ស្នាច់ អ! ទៅបានឆ្ងាយដែរអ៊ីនោះ?

គួន ៖ បាទ!

ធានី ៖ តែកាលអ៊ំមកអត់មកតាមផ្លូវនឹងទេ?

គួន ៖ អត់ទេ។

ធានី ៖ មកតាមផ្លូវលំទងវិញ?

គួន ៖ អឺ!

ធានី ៖ ម៉េចចឹង បើអានោះមានថ្នល់ អានោះយើងដើរក្នុងព្រៃ?

គួន ៖ បើខាងនោះអត់ហ៊ានដើរ។

ធានី ៖ ម៉េចចឹង?

គួន ៖ វាស្ពាន វាអូរច្រើន ហើយដើរនេះមានអូរផាល ហើយមកអូរលំទងយើង អូរជីកយើង វាអូរតិច មានតែអូរពីរ។ ដល់យើងដើរនោះអូរច្រើនយ៉ាប់។

ធានី ៖ អូរច្រើនពិបាកដែរ?

គួន ៖ វាឆ្ងល់ ហើយឡានមកអត់រួច ។

ធានី ៖ កាលនឹងឡានមក២នឹង ដឹកៗតែអង្ករ?

គួន ៖ ដឹកស្បៀង ។

ធានី ៖ ដឹកតែអង្ករ?

គួន ៖ អង្ករ ។

ធានី ៖ ក្រៅពីនឹងអត់មានដឹកអី?

គួន ៖ អត់ទេ ។

ធានី ៖ អង្ករប៉ុន្មានបាវទៅ មួយឡាន?

គួន ៖ អង្ករមួយឡានប៉ុន្មាន៥០បាវ ។

ធានី ៖ ចឹងអកស្រុកនៅនឹងអត់អង្ករហូបបានយើងដឹកមក?

គួន ៖ មាន ប៉ុនយើងអង្ករទាហាន ថាយើងរកស៊ីអង្ករអត់ទាន់បាន ។ ស្រុកនេះមិនជាអត់ជាឃ្លានអីប៉ុន្មានទេ ។ ខែចូលឆ្នាំនឹង ឡើងគេអត់ប្រើស្ករទេ ស្រុកនេះ គេប្រើទឹកឃ្មុំ ។ ចូលឆ្នាំគេប្រើទឹកឃ្មុំ ឧបមាថាលំទងមកក៏២កាន៣កាន យកមកលេងជុំគ្នា អន្ទង់វែង ។

ធានី ៖ ចូលឆ្នាំនឹង?

គួន ៖ បាទ!

ធានី ៖ ចូលឆ្នាំនឹង យកទឹកឃ្មុំយកមកធ្វើអីគេ?

គួន ៖ មកអ្នកណាចង់ធ្វើអីអន្សមអីជ្រលក់ទឹកឃ្មុំ ។

ធានី ៖ ចឹងសំបូរហើយមើលទៅ?

គួន ៖ សំបូរ ឃ្មុំមួយដើម៥០០សំបុកអាខាងលើស្ពានអូរជីកយើង ប៉ុនផាប់អស់ហើយ ហៅភូមិតាប៉ែតៗ ។

ធានី ៖ ភូមិតាប៉ែន កាលមុនកន្លែងនឹងភូមិឃ្មុំ?

គួន ៖ បាទ! ឃ្មុំមើលទៅឡើងខ្មៅ៥០០សំបុក គាត់ឡើងយកកូនកំលោះកូនក្រមុំ យើងដើរទៅចាំយកទឹកមួយលីត្រពីរលីត្រទៅ កូនយកប៉ុនណាយកទៅ គេបញ្ចូលអង្គុយចាំយក ។

ធានី ៖ កាលមុនច្រើន?

គួន ៖ បាទ! ច្រើន ។

ធានី ៖ ចឹងស្អីក៏មានហូបដែរ បរិបូរម៉ង?

គួន ៖ មាន អត់ខ្វះទេ និយាយពីម្ហូបវិញសំបូរ ។

ធានី ៖ ស្អីខ្វះទៅ មើលនិយាយសត្វ?

គួន ៖ សត្វតាំងពីឈ្លូស ប្រើស អណ្ដើក ត្រកួត ឡើង ។

ធានី ៖ អ! មាននៅតាមអូរយើងនឹង?

គួន ៖ តាមវាលយើង តាមនៅនេះរកអណ្ដើក ។

ធានី ៖ មានអណ្ដើកដែរ?

គួន ៖ បាទ!

ធានី ៖ អណ្ដើកនឹងវានៅតែក្នុងទឹកតើអ៊ំ?

គួន ៖ ទេ! នោះអណ្ដើកព្រេច នៅគោកក៏មានទឹកក៏មាន ។

ធានី ៖ អណ្ដើកព្រេចនឹងអណ្ដើកប៉ុន្មាន?

គួន ៖ ប៉ុនៗនេះ ។

ធានី ៖ ប៉ុនដុំឥដ្ឋទេ ធំជាងដុំឥដ្ឋ?

គួន ៖ នោះហើយ ។

ធានី ៖ អណ្ដើកនឹងអត់មានធំជាងនឹងទៀតទេ?

គួន ៖ អត់ទេ ។

ធានី ៖ អណ្ដើកនឹងអណ្ដើកតូចៗ?

គួន ៖ បាទ! គេហៅអណ្ដើកព្រេច ។ បើអណ្ដើកទឹកគេមានអាចប៉ុននេះៗ ។

ធានី ៖ ចឹងអណ្ដើកនឹងនៅតែក្នុងទឹក?

គួន ៖ បាទ! មានខែគេវាឡើងលើគោកខ្លះ ទឹក ។

ធានី ៖ ចឹងមានគ្រប់តែសត្វ?

គួន ៖ បាទ! មានច្រើនណាស់ តាំងពីខ្លា ដំរី ។

ធានី ៖ មានសត្វដែលកម្រ ដូចថានៅខាងស្រុកក្នុងយើងអត់ដែលឃើញ មកនេះយើងឃើញមាន ទេ?

គួន ៖ អត់ទេ អត់ឃើញអីទេ ហើយពស់ ច្រើនពស់ ។

ធានី ៖ ច្រើនជាងគេគឺ ពស់?

គួន ៖ បាទ!

ធានី ៖ អត់មានក្រពើ?

គួន ៖ ក្រពើអត់ដែលប៉ះដែរ ។

ធានី ៖ មានច្រើនជាងគេគឺ ពស់?

គួន ៖ បាទ! ឮតែគេថាក្រពើៗ ប៉ុនអត់ដែលប៉ះ ស្រុកនេះគេច្រើនតែ ខែប្រាំងចេះ ទឹកអូរជីក រីង គេរៃសំបករីង គេបំពុលយកត្រីៗ

ធានី ៖ អូ! មានត្រីច្រើនទេ?

គួន ៖ បាទ! រៃដីមួយគីឡូទៅចាប់ ឲ្យវាពុលទៅដើរដួសយកៗ

ធានី ៖ ហើយត្រីភាគច្រើនត្រីនៅនឹងត្រីអ់?

គួន ៖ ត្រីច្រើនត្រីស ត្រីគ្រប់ធុនៗ

ធានី ៖ មានត្រីអីខ្លះ?

គួន ៖ ត្រីស ត្រីឆ្ដាំង ត្រីអណ្ដែងអត់ហើបទេ សុទ្ធត្រីភ្អក់ ភាគច្រើនត្រីស ត្រីឆ្ដាំង ត្រីក្អួន ត្រីភ្អក់ៗ

ធានី ៖ ត្រីសនឹង ត្រីម៉េចទៅ?

គួន ៖ អាត្រីលកតាមផ្សារស្រេកាល្អិត ត្រីសស្កុះប៉ុនៗនេះៗ

ធានី ៖ ត្រប៉ែតទេ?

គួន ៖ ត្រប៉ែក ប៉ុនអត់វែងៗ

ធានី ៖ ត្រីកំភ្លាញ?

គួន ៖ បាទ! ត្រីកំភ្លាញ ត្រីសៗ

ធានី ៖ អានឹងហៅត្រីស?

គួន ៖ បាទ!

ធានី ៖ មានសំបូរតែត្រីចឹងៗ?

គួន ៖ បាទ!

ធានី ៖ ហើយសំបូរអីហូប?

គួន ៖ សំបូរៗ

ធានី ៖ ហើយស្រែចំការអីធ្វើបានដែរ?

គួន ៖ ស្រែធ្វើបានអាខាងលិចអន្លង់វែងអាវាលធំនឹងៗ

ធានី ៖ ទៅធ្វើតែកន្លែងនឹងទេ?

គួន ៖ បាទ!

ធានី ៖ ហើយប្រជាជនទាំងអស់នៅអន្លង់វែងនឹងទៅធ្វើនឹងទាំងអស់គ្នា?

គួន ៖ បាទ! ទៅធ្វើនឹងៗ

ធានី ៖ ចុះដូចខាងលំទេងអីគេទៅធ្វើនៅ?

កូន ៖ គេធ្វើដោយឡែកគេ ខាងផ្ទាវគេធ្វើនោះផ្សេងទៀត គាដេវនេះទៀត ។

ធានី ៖ ដល់ពេលខាងអ៊ំខាងទ័ពនឹងគឺ ធ្វើនៅខាងនឹងឯង ធ្វើទ័ពផង យាមផង ហើយក្រៅពីការយាមនៅលើភ្នំ គឺយើងចុះមកក្រោម?

កូន ៖ បែកគ្នា ខ្លះនៅនេះនៅធ្វើស្រែ អាអ្នកនៅមុខ ។

ធានី ៖ នៅយាមទៅ?

កូន ៖ បាទ!

ធានី ៖ បានអីហូបដល់ពេលយើងយកទៅ?

កូន ៖ សាច់ធម្មតា ។

ធានី ៖ យើងរកសាច់ខ្លួនឯង ឬមួយក៏?

កូន ៖ សាច់ខ្លួនឯង ។

ធានី ៖ ដល់ពេលអង្ករយើងយកពីនោះមក?

កូន ៖ បាទ! អង្ករ ។

ធានី ៖ ចឹងអត់មានខ្វះហូប?

កូន ៖ អត់ទេ ។

ធានី ៖ បរិបូរម៉េង?

កូន ៖ វាខ្វះដែរ គេឲ្យស៊ីបបរប៉ុនគេដឹកអង្ករទៅឲ្យមយក្រុមខ្ញុំ១០នាក់ មួយអាទិត្យគេដឹកអង្ករឲ្យមួយបាវ អត់ហូបអស់ទេ ពេលគេអត់ដឹកអង្ករទៅឲ្យយើងហូបបបរទៅ ហើយបើអត់ខ្វះយើងបាយ ធ្វើការចាក់ចំរូង ធ្វើការលើភ្នំ ។

ធានី ៖ ធ្វើការចាក់ចំរូងធ្វើអី?

កូន ៖ បិទចំរូងចាក់តាមជើងភ្នំ ។

ធានី ៖ ដាក់ចឹងធ្វើអី?

កូន ៖ ដឹងគេឲ្យដាក់ ។

ធានី ៖ នៅភ្នំយើងបិទខាង?

កូន ៖ វាមានពីរជាន់ អាមួយជាន់ទៅធ្វើការនៅខ្នង អាមួយជាន់ធ្វើការជើងភ្នំ ហើយ៣ជាន់អ្នកនៅអន្លង់វែង ។

ធានី ៖ ចឹងវាមានគន្លាក់ៗវាចឹង?

កូន ៖ បាទ!

ធានី ៖ ហើយចឹងយើងដើរមិនស្រួលៗប៉ះចំរូងអត់?

គួន ៖ អត់ទេ វាមានខ្សែ យើងដាក់តាមខ្សែវា ។

ធានី ៖ យើងមើលដែល ច្រកណាយើងអាចចេញបាន?

គួន ៖ ថ្ងៃណាយើងដើរទៅប៉ះណាអណ្តើកធ្លាក់អន្ទង់ចំរូង អន្ទង់ស្មៅៗចង្អេះ ដើរមួយព្រឹកទៅក៏បាន ៤-៥ អណ្តើក ។

ធានី ៖ ចឹងតាមពិតដាក់អន្ទង់នឹងដាក់យកសត្វទេ ហើយ?

គួន ៖ ទេ! ដាក់យកក្រែងកាលនោះដាក់យកប៉ាវ៉ាចុះ ។

ធានី ៖ មានប៉ាវ៉ាមកដែរ?

គួន ៖ មានទាហានប៉ាវ៉ា នៅស្ងាច់ ។

ធានី ៖ ប៉ាវ៉ានឹងខាងណា?

គួន ៖ ទាហាន អ៊ិន តាំ ។

ធានី ៖ អ៊ិន តាំ ក្រែងគាត់អ្នកធ្វើទាហាននៅតាមព្រំដែននឹង?

គួន ៖ បាទ! មានទាហានយូរហើយ ។

ធានី ៖ គេហៅទាហានចឹងម៉ង?

គួន ៖ បាទ!

ធានី ៖ ដែលធ្លាប់ចាប់បាន?

គួន ៖ អត់ទេ ។

ធានី ៖ អត់ដែលចាប់?

គួន ៖ អឺ!

ធានី ៖ ដែលធ្លាប់ឃើញ វ៉ៃជាមួយគាត់?

គួន ៖ ឃើញ ។

ធានី ៖ ធ្លាប់ឃើញ តែបានវ៉ៃជាមួយគ្នាអត់?

គួន ៖ បាទ! វ៉ៃជាមួយគ្នា ។

ធានី ៖ មានចាប់បានរស់អត់?

គួន ៖ អត់ ។

ធានី ៖ មានបាញ់ស្លាប់អី?

គួន ៖ គេចុះទៅ ខាងនោះគេចុះទៅឃោសនាប្រជាជនទៅវ៉ាវិន ទៅនេះគេហៅទ្រំជ្រួយឆ្នួន ។

ធានី ៖ គេហៅស្អីគេ?

គួន ៖ ទ្រំជ្រួយឆ្នួន ។

ធានី : ទ្រំជ្រួយផ្នួន?

គួន : បាទ!

ធានី : កន្លែងនឹងស្អីគេ?

គួន : ភូមិគេ ប្រជាជនអីរត់ឡើងទៅលើ ។

ធានី : អ៊ំដែលធ្លាប់បានដឹងរឿងនឹងដែរ?

គួន : បាទ!

ធានី : ធ្លាប់ឃើញ អ៊ិន តាំ ទេ?

គួន : ទេ! អត់ឃើញរូបទេ ឃើញតែទាហាន តាមវ៉ៃដល់ ។

ធានី : ហើយម៉េចក៏គាត់ទៅវ៉ៃតាមភូមិយើងធ្វើអីនោះ?

គួន : មិនដឹងម៉េច វ៉ៃយកសំណាកនៅអី តែអត់វ៉ៃបាន ។

ធានី : ចឹងពេលដែលអ៊ំឡើងលើភ្នំធ្វើការនៅតាមឡូកនឹង ចឹងអ្នកណាគេធ្វើប្រធានក្រុមអ៊ំ? ឬអ៊ំអ្នកធ្វើ?

គួន : អត់ទេ ខ្ញុំអត់ដែលបានធ្វើ ប្រជាជនសុទ្ធ ។

ធានី : អ៊ំធ្វើធម្មតា ។ ចឹងនៅក្រុមអ៊ំ អ្នកណាគេដឹកនាំឡើងក្រុម?

គួន : មានអា ហ៊ាប ។

ធានី : ឈ្មោះ ហ៊ាប ៗ នឹងជាប្រធានអីគេ?

គួន : ប្រធានក្រុម ។

ធានី : ប្រធានក្រុមគ្នាបន្ទាននាក់ទៅ មួយក្រុម?

គួន : មួយក្រុមមាន១០នាក់ ។

ធានី : ចឹងតែម៉ាឡូក់មួយយើងត្រូវការពារ៣០នាក់?

គួន : បាទ! អានឹងមួយកងតូច ។

ធានី : ក្នុងមួយកងតូចនឹង អ្នកណាគេ?

គួន : ជូ ។

ធានី : ចុះកងធំឈ្មោះ អូរ?

គួន : បាទ!

ធានី : ចឹងជាទូទៅនៅពេលដែលបទបញ្ជាចេញមកយើងទទួលពីណាមក ពី ជូ នឹង ឬពី ជាតិ?

គួន : ទទួលពីកងតូច ។

ធានី : ថាយើងត្រូវធ្វើអី ដាក់បិទចំរូង ឬក៏ត្រូវធ្វើអីនឹង យើងប្រាប់ដែរអត់?

គួន ៖ គេប្រាប់ជុំគ្នានេះ ឧបមាថាព្រឹកនេះយើងត្រូវធ្វើអីត្រូវបិទចំរូង ជុំគ្នាពេលនេះជាមួយក្រុមយើង ។

ធានី ៖ ក្នុងក្រុមយើងប្រជុំធ្វើការងារនឹងទៅ?

គួន ៖ បាទ!

ធានី ៖ ហើយដល់ពេលអ៊ំនៅមួយខែនៅលើភ្នំ មួយខែចុះមកក្រោម?

គួន ៖ បាទ! ចុះដូរគ្នា ។

ធានី ៖ ចុះមកក្រោមហើយ?

គួន ៖ ចុះនឹងចុះតាមជាន់ថ្នាក់ ចុះពីលើខ្នងមកនៅលើភ្នំម៉ាខែបានមកនៅនេះទៀត នៅសេដ្ឋកិច្ច ។

ធានី ៖ វិលចឹងរហូត?

គួន ៖ បាទ! នៅធ្វើស្រែ ។

ធានី ៖ ហើយដែលធ្លាប់មានសត្វព្រៃវាផ្តាលមកម្តងៗមានទេ?

គួន ៖ មានបាញបានដូចសត្វជ្រូក ឈ្លូស ទន្សោង បាញ់បានមួយគគោក ថ្ងៃណាបាន៧ ។

ធានី ៖ តែពេលដែលអ៊ំធ្វើការចឹងមក អ៊ំធ្វើនៅនឹងរហូតដល់បែកម៉ង?

គួន ៖ បាទ!

ធានី ៖ នៅលើភ្នំនឹងរហូត?

គួន ៖ នៅលើភ្នំ ។

ធានី ៖ នៅតំបន់ ចឹងរហូតដល់អ៊ំស្គាល់ភូមិសាស្ត្រអស់ហើយ?

គួន ៖ ស្គាល់មួយចំនួន ។

ធានី ៖ ហើយពេលមកដល់អន្លង់វែងចឹង នៅកន្លែងយើងនឹង កន្លែងស្រុករាល់ថ្ងៃនឹង ទីចាត់ការចាស់របស់គេនៅនឹងដែរ?

គួន ៖ បាទ! ទីចាត់ការគេនៅនឹងកន្លែងវត្ត ។

ធានី ៖ ចឹងមុននឹងអ៊ំនិយាយថា នៅឆ្នាំ៧៧យោធាខាង ជាតិ នឹង ឈ្មោះ ជាតិ គាត់នឹងចាប់ផ្តើមជម្លៀសប្រជាជនឲ្យចេញមែនទេ?

គួន ៖ បាទ!

ធានី ៖ ជម្លៀសប្រជាជនគ្រប់ភូមិទាំងអស់?

គួន ៖ គ្រប់ទាំងអស់មួយស្រុកអន្លង់វែង ។

ធានី ៖ ម៉េចចឹងបានគេជម្លៀសឲ្យគាត់ចេញ?

គួន ៖ មិនដឹងម៉េច ។

ធានី ៖ តែអ៊ំបានចូលរួមដែរអត់ទេ?

គួន ៖ អត់ទេ ។

ធានី ៖ ចុះម៉េចបានអ៊ំដឹង?

គួន ៖ ទេ គ្រាន់តែឃើញជម្លៀសទៅ ឲ្យប្រជាជនចេញ ដឹកជញ្ជូនចេញដឹកគោទៅ ។

ធានី ៖ តែខាងទ័ពវិញ យើងអត់មានខាងយុត្តិសាស្ត្រអីបានឲ្យប្រជាជនចេញទេ?

គួន ៖ អត់ទេ ។

ធានី ៖ តែមានដឹងថាមានអ្នកណាគេក្បត់ មានអ្នកណាគេអីដែរអត់បានឲ្យចេញ?

គួន ៖ អត់ទេ បើខ្ញុំយុទ្ធជនអត់ដឹងរឿង ។

ធានី ៖ ម៉េចទៅអ៊ំ?

គួន ៖ ទេ! មិនដឹងរឿងថាអ្នកណាណាគេក្បត់ ខ្ញុំនៅតែមុខៗ តែក្រោយក៏មក ។

ធានី ៖ មកធ្វើការធម្មតា?

គួន ៖ មកៗក៏យើងនៅក្រោមបញ្ជាគេដែរ យើងយុទ្ធជន ។

ធានី ៖ ចឹងអ៊ំនៅយោធាយើង នៅក្រោមការគ្រប់គ្រងរបស់អ្នកណាគេដែរ យោធានៅស្រុក ដូចថា អ៊ំមកយាមតាមព្រំដែន ក្រោមការគ្រប់គ្រងរបស់អ្នកណាគេ របស់ទ័ពណា ខាងណា ខាងមជ្ឈិម ខាងតំបន់ ខាង?

គួន ៖ ខាង តា ពក នឹងអ្នកនេះ កែ ពក ន់ង ។

ធានី ៖ ខាងភូមិភាគ?

គួន ៖ បាទ!

ធានី ៖ អ៊ំដឹងថា កែ ពក គាត់ជាអ្នកណា?

គួន ៖ កែ ពក នៅនឹង ថាសព្វថ្ងៃងាប់បាត់ហើយ ។

ធានី ៖ តែចង់សួរថា កាលនឹងអ៊ំដឹងថា កែ ពក នឹងកាលសម័យកសាង សម័យ៣ឆ្នាំយើងនឹង គាត់មានងារជាអីគេ បន្ទាប់ពីធ្វើជាយោធា?

គួន ៖ ខ្ញុំអតដឹងរឿងគេទេ ។

ធានី ៖ តែដឹងថា កែ ពក នឹងគាត់អ្នកនៅគ្រប់គ្រងរបស់អ៊ំដដែល?

គួន ៖ បាទ!

ធានី ៖ ចឹង តា ពក នឹងអ្នកគ្រប់គ្រងរហូត?

គួន ៖ បាទ! តាំងពីទាហានលន់ នល់ មក ។

ធានី ៖ រហូតមកដល់យើងឥឡូវដែរ?

គួន ៖ បាទ! ដល់គាត់ស្លាប់ ។

ធានី ៖ ដល់គាត់ស្លាប់ម៉េង?

គួន ៖ ដល់គាត់ស្លាប់នេះ មុននឹងស្លាប់ គាត់នៅក្រោមបទបញ្ជា តា ម៉ុក ។

ធានី ៖ តែមុននឹង អត់ដឹង ថាគាត់នៅក្រោមបទបញ្ជាអ្នកណាគេទេ?

គួន ៖ អត់ទេ! មុនគាត់ស្លាប់នេះ គាត់នៅក្រោមបទបញ្ជា តា ម៉ុក ។

ធានី ៖ ចឹងគាត់ស្លាប់ឆ្នាំប៉ុន្មាន?

គួន ៖ ទេ! ដឹងស្លាប់ឆ្នាំប៉ុន្មាន ឮថាស្លាប់ៗ មិនបានជាចាប់អារម្មណ៍អារឿង ។

ធានី ៖ ស្រេចគេមេយើង?

គួន ៖ អឺ! អាងតែគេមេទៅហើយ ។

ធានី ៖ ចឹងអ៊ីដល់ពេលប្រជាជនជម្លៀសទៅក្រឡាញ់អស់ទៅ នៅអន្លង់វែងយើងមានតែទ័ពទេ?

គួន ៖ ទ័ព និង ពេទ្យ ។

ធានី ៖ ចុះមានប្រជាជនថ្មីអីជម្លៀសមកនឹងទេ?

គួន ៖ អត់ទេ អត់មាន ។

ធានី ៖ ចុះមុននឹងអី ក៏អត់មានដែរ មានតែអ្នកចាស់?

គួន ៖ អត់មាន បាទ!

ធានី ៖ អត់មានប្រជាជនថ្មីជម្លៀសមកអន្លង់វែងទេ?

គួន ៖ អត់មានទេ ។

ធានី ៖ មានតែអ៊ីដែលជាយោធាដែលមក ហើយនឹងអ្នកចាស់នៅនឹង?

គួន ៖ បាទ!

ធានី ៖ ដល់ពេលឆ្នាំ៧៧ទើបបានមានការផ្លាស់ប្តូរ?

គួន ៖ បាទ!

ធានី ៖ ហើយដល់ពេលផ្លាស់ប្តូរចឹង អត់មានលែងមានប្រជាជនរស់នៅហើយ ចឹងអ្នកដែលគ្រប់គ្រងនៅនឹងក៏អត់មានដែរ?

គួន ៖ អត់មានទេ ។

ធានី ៖ មានតែយោធាអ្នកគ្រប់គ្រងនៅនឹង?

គួន ៖ មានតែយោធា ។

ធានី ៖ ហើយយោធានឹង គឺមាន ជាតិ នឹងជាអ្នក?

គួន ៖ យោធានឹង ធ្វើស្រែខ្លួនឯង ចម្បាំងខ្លួនឯង ។

ធានី : តែដល់ពេលកន្លែងផ្ទះ តា ម៉ុក នៅរាល់ថ្ងៃនឹង គឺកាលមុនភ្នំសោះ?

គួន : បាទ! គេហៅកូនភ្នំ ។

ធានី : កូនភ្នំ តែជុំវិញនឹងវាមានទឹកដដែល?

គួន : មានទឹក ។

ធានី : មានទឹកព័ទ្ធជុំវិញ ហើយកោះកូនភ្នំមួយកោះលើនឹង?

គួន : ដែលមានវាអត់មានផ្លូវចូល មានផ្លូវដើរ តែអត់មានអ្នកណាហ៊ានចូលផង មានដើរឈើ យាង ឈើអីធំៗ ។

ធានី : ចឹងនៅកោះនឹងមានដើមឈើយាងច្រើន?

គួន : បាទ! ឈើធំៗ តាំងពីមាត់អូរដើកទៅឈើម្ចប់ត្រលឹងដូចព្រៃអន្លរចឹង ។

ធានី : តែអត់មានអ្នកណាគេកាប់មានអីទេ?

គួន : អត់ទេ ។

ធានី : យើងនៅការពារទាំងអស់គ្នា?

គួន : បាទ!

ធានី : តែធ្លាប់មានថៃមានអីគេមកលួចកាប់ឈើ?

គួន : អត់ទេ អត់មានទេ ។

ធានី : មានតែទ័ពប៉ារ៉ា?

គួន : បាទ! ប៉ារ៉ាមកម្ដងៗយើងដេញតាមដល់វារិន តាមវៃគ្នា ។

ធានី : តែអកភូមិវារិនអីក៏អត់ធ្លាប់មកនេះដែរ?

គួន : អត់ទេ ។

ធានី : មានតែទ័ពយើងនៅ?

គួន : បាទ!

ធានី : នៅរហូតដល់ពេលណា?

គួន : នៅរហូតលុះសព្វថ្ងៃ ។

ធានី : តែកាលពេលវៀតណាមចូលមក អ៊ំបានដឹងទេ?

គួន : ដឹង ។

ធានី : ដឹងថាវៀតណាមចូលស្រុកខ្មែរយើងទេ?

គួន : ខ្ញុំទៅវៃនឹងវាលង្អើប ។

ធានី : វាលអីគេ?

គួន ៖ វាឆ្អើប ខាងជើង អឺ!ខាងត្បូងសំរោង ។

ធានី ៖ គេហៅវាឆ្អាប?

គួន ៖ ឆ្អើបៗ ខាងជើងចុងកល្ប ថាចុងកល្បតែម្តង ។

ធានី ៖ ចឹងនៅឆ្នាំ៧៩នឹង អ៊ំឡើងទៅវៃនៅចុងកល្ប?

គួន ៖ បាទ!

ធានី ៖ ឡើងវៃជាមួយវៀតណាមនឹង?

គួន ៖ បាទ!

ធានី ៖ ហើយវៃរហូតដល់ពេលណាទៅ?

គួន ៖ វៃគ្នាតែពីរថ្ងៃទេ ចាញ់គេក៏បេះតែរត់ទៅ ។

ធានី ៖ អ៊ំរត់?

គួន ៖ អឺ!

ធានី ៖ ចាញ់ហើយពេលនឹង?

គួន ៖ ចាញ់ ។

ធានី ៖ កាលនឹងអ៊ំកាន់កាំភ្លើងអីគេ?

គួន ៖ ហ៑! យុទ្ធជន កាន់អាកា ។

ធានី ៖ អាកា យើងទៅសមរភូមិមុខ?

គួន ៖ បាទ!

ធានី ៖ ហើយយើងចាញ់គេយើងទៅណាទៅ?

គួន ៖ រត់ឡើងលើភ្នំ ។

ធានី ៖ រតឡើងភ្នំដងរែកម៉ង?

គួន ៖ បាទ!

ធានី ៖ កាលនឹងគេមានដាក់ជាច្រកជាអីនៅ?

គួន ៖ រត់ឡើងលើភ្នំទៅជុំគ្នាឯលិចស្នាច់ អាមុខអណ្តែងមុតនឹង ជុំជើងគ្នាទៅបានបំបែកគ្នាមកធ្វើការនេះ ។

ធានី ៖ ណាត់គ្នាមុនៗពេលបែករត់នឹង?

គួន ៖ អត់ទេ ។

ធានី ៖ ធ្វើម៉េចបានទៅជុំគ្នានឹង?

គួន ៖ ចុះបើអត់បាយស៊ីយើងរត់ទៅជុំគ្នា ។

ធានី ៖ នៅស្ទាច់?

កូន ៖ នៅស្ទាច់ ។

ធានី ៖ តែនៅជើងភ្នំ ឬនៅលើភ្នំ?

កូន ៖ នៅលើភ្នំ ។

ធានី ៖ លើភ្នំ តែខាងស្ទាច់?

កូន ៖ នៅខាងគេហៅត្រង់ណាទេលិច មួយជួរអូរគគីរ ៗនឹងឯង ដូចជប់គគីរ ។

ធានី ៖ ម៉ុំជប់គគីរ?

កូន ៖ បាទ! ទៅនៅជុំគ្នាបានចែកកម្លាំងគ្នាធ្វើការ ៗ វៃយួនមួយសារទៀតទៅៗបាន តា ម៉ុក មក ដល់ ។ តា ម៉ុក ទើបមកក្រោយទេ ។

ធានី ៖ ចឹងវៃយួនមួយសារទៀត វៃពេលណាទៅ ព្រោះ៧៩អីរត់ហើយ?

កូន ៖ បាទ! រៀបកម្លាំងដែលរត់នឹង ។

ធានី ៖ រត់បណ្តើរ រៀបបណ្តើរ?

កូន ៖ បាទ! រៀបកម្លាំងវៃបាន ។

ធានី ៖ ទប់បានប៉ុន្មានខែ បាន?

កូន ៖ ទៅបានគេនៅតាមជើងភ្នំនេះគេទាំងអស់ ពួកវៀតណាម យើងនៅលើខ្នង ។

ធានី ៖ យើងនៅលើខ្នងភ្នំវិញ?

កូន ៖ បាទ!

ធានី ៖ យោធាយើងនឹង ដែលទ័ពខាង ជាតិ អ្នកគ្រប់គ្រងនឹង គឺនៅលើភ្នំទាំងអស់?

កូន ៖ បាទ!

ធានី ៖ ហើយម៉េចទៀតទៅអ៊ំ?

កូន ៖ ហើយបានចុះ ។

ធានី ៖ ឆ្នាំប៉ុន្មាន ដែលយើងដែលខាងវៀតណាមគេចូលដល់អន្លង់វែង ហើយយើងរត់ឡើងលើខ្នងភ្នំ?

កូន ៖ ៧៨ ៧៩ ។

ធានី ៖ ៧៩ដែរ ខែប៉ុន្មាន អ៊ំចាំ?

កូន ៖ អត់ចាំបានទេ ។

ធានី ៖ តែកាលនឹងខែប្រាំង ខែវស្សា?

កូន ៖ ខែវស្សា ។

ធានី ៈ ពេលយើងរត់ឡើងភ្នំនឹង យើងខែវស្សា?

គួន ៈ ចាប់ផ្ដើមពីខែប្រាំង ។

ធានី ៈ ហ្នឹងហើយចាប់ផ្ដើមពីខែប្រាំង ប៉ុន្តែដល់ពេលអីឡើងភ្នំខែវស្សា?

គួន ៈ បាទ!

ធានី ៈ ចឹងអាចថាខែវស្សា៧៩?

គួន ៈ បាទ!

ធានី ៈ ខែវស្សា៧៩នឹង គឺវៀតណាមគ្រប់គ្រងនៅអន្លង់វែង ហើយអីឡើងភ្នំ?

គួន ៈ បាទ! វៀតណាមគ្រប់គ្រងដល់ជើងនឹង ។

ធានី ៈ ដល់ជើងភ្នំដងរែកយើង?

គួន ៈ បាទ!

ធានី ៈ ហើយយើងទៅជួបគ្នានៅជប់គគីរ?

គួន ៈ បាទ!

ធានី ៈ នៅជុំគ្នាហើយម៉េចទៀត?

គួន ៈ បំបែកកម្លាំងគ្នា ធ្វើការវ៉ៃវៀតណាម ។

ធានី ៈ តែយើងទទួលបញ្ជាពីណាមក បានឲ្យយើងគេបំបែក?

គួន ៈ កាលនោះ ខ្ញុំមិនបានសួរដឹងរឿងដែរ ។

ធានី ៈ តែអ្នកណាគេអ្នកបញ្ជាអី?

គួន ៈ ទេ! កាលនោះដូចជា ទេ!កាលនោះ តា រ៉េត១ តា សឿន ។

ធានី ៈ តា រ៉េត, តា សឿន នឹងគាត់ជាអ្នកណាគេ គាត់ងារជាអីគេ?

គួន ៈ ជាមេធំនៅនោះឯកងវរៈ ។

ធានី ៈ កងវរសេនាតូច វរសេនាធំ?

គួន ៈ វរសេនាធំ ។

ធានី ៈ កងវរសេនាធំ?

គួន ៈ តា រ៉េត អនុ, តា សឿន ប្រធាន ។

ធានី ៈ ហើយ តា ជាតិ ប្រធានដដែល?

គួន ៈ ហ៎! ជាតិ គេដកហើយ ដកទៅក្រឡាញ់-កំពង់ថ្កូវទៅបាត់ ។

ធានី ៈ ដកតាំងពីពេលណា ៧៧ហ្នឹង?

គួន ៈ បាទ!

ធានី ៖ ចឹង១៩៧៧ ជាតិ នឹងគេដកទៅក្រឡាញ់-កំពង់ថ្កូវវិញ?

គួន ៖ បាទ!

ធានី ៖ ហើយបាត់ខ្លួនរហូត?

គួន ៖ បាត់ខ្លួនរហូត ។

ធានី ៖ តែអត់ដឹងមូលហេតុអីទេអ៎?

គួន ៖ អត់ដឹងរឿង ។

ធានី ៖ ចុះ តា រ៉េត ហើយនឹង តា សឿន នឹងមកជំនួសជាតិនឹងវិញ?

គួន ៖ ហ៎! ដែលទៅជុំគ្នានៅជប់គគីរនោះ តា រ៉េត, តា សឿន បានគេគ្រប់គ្រង ។ ចុះដែលត្រូវដាច់មេដាច់កើយអស់ហើយនោះ ។

ធានី ៖ ប៉ុន្តែចង់និយាយថា បើពេល ជាតិ ដកទៅ៧៧ អ្នកណាគេអ្នកគ្រប់គ្រងជំនួសគាត់វិញ?

គួន ៖ អត់មានទេ ។

ធានី ៖ ចឹងអ្នកណាគេធ្វើមេ?

គួន ៖ រំលាយទ័ពអស់ ។

ធានី ៖ រំលាយទ័ព ចឹងអត់មានអ្នកណាគេការពារអ្នកណាគេ?

គួន ៖ អត់មានការពារអីទេ មានយុទ្ធជនរៀងខ្លួន មានមេដែរ ក៏ប៉ុន ។

ធានី ៖ អត់មានមេធំទេ?

គួន ៖ បាទ!

ធានី ៖ ចឹងធ្វើម៉េចយើងធ្វើការអីកើតទៅ បានបញ្ជាពីណាមកគ្រប់គ្រង?

គួន ៖ មានតែ តា សឿន, និង តា រ៉េត នេះគេជាអ្នកគ្រប់គ្រងគេ ។

ធានី ៖ ចឹង តា សឿន, តា រេត នឹង ពេលដែល ជាតិ ទៅ គឺ តា សឿន, តា រ៉េត នឹងគាត់អ្នកគ្រប់គ្រងជំនួស?

គួន ៖ បាទ!

ធានី ៖ ហើយគាត់មកពីណាវិញ?

គួន ៖ អត់ដឹងមកពីណាដែរ ទៅជុំគ្នានៅអណ្តែនមុគជប់គគីរនោះទៅ បានចែកកម្លាំងគ្នាធ្វើការវ៉ៃយួន ។

ធានី ៖ ប៉ុន្តែចង់និយាយថា ពេលដែល ជាតិ ទៅ គឺ តា សឿន, តា រ៉េត នឹងមកដល់?

គួន ៖ បាទ!

ធានី : ហើយគាត់នឹងនិយាយរដឹនដែរអត់ទេ គាត់មកពីភូមិភាគណា អ៊ំដឹងទេ តា សឿន, តា រ៉ែត?

គួន : ហ៎! នៅថានៅសៀមរាប តា សឿន, នែក! តា រ៉ែត នោះណា ។

ធានី : ចុះ តា សឿន?

គួន : ហ៎! មិនដឹងមកពីណា រដឹន មិនដឹងឆ ។

ធានី : អត់ប្រាប់ថាមកពីភូមិភាគអី?

គួន : អត់ទេ ។

ធានី : តែដល់ក្រោយមកអ៊ំដឹងថា មកពីខេត្តណា?

គួន : អត់ទេ ។

ធានី : អត់ដឹងដែរ?

គួន : រករៀបសួរ អត់ដែលបានទៅសរ ។

ធានី : តែ រ៉ែត នឹងដឹងថាអ្នកសៀមរាប?

គួន : បាទ! ហើយអត់នឹង តា សឿន នឹងទៅបានឃើញ តា ម៉ុក មក ។

ធានី : ឆ្នាំប៉ុន្មាន អ៊ំរកនឹកមើល?

គួន : អូ! ដែលចាំបានទេ ។

ធានី : ព្រោះអីកាលដែល៧៩ ខែវស្សានឹងយើងឡើងលើភ្នំ?

គួន : តា សឿន នៅបាន៣ឆ្នាំ ។

ធានី : ៣ឆ្នាំ ៧៩ ៨០ ៨១?

គួន : បាទ! បានឃើញ តា ម៉ុក មកដល់ ។

ធានី : តា ម៉ុក មកដល់ទើបឆ្នាំ៨០ ៨១នឹងទេ?

គួន : ៨១ ។

ធានី : ចឹងកាលមុនអ៊ំអត់ដែលដឹងថា តា ម៉ុក មក?

គួន : អត់ដែលឃើញមុខផង ដែលឮឈ្មោះ ។

ធានី : ចឹងកាលយើងនៅដំបូងនឹង យើងមានតែទ័ពយើងទេ នៅដងរែក?

គួន : បាទ! ទ័ពសុទ្ធ ។

ធានី : អត់មាន តា ម៉ុក តាអីណា?

គួន : អត់មាន ប៉ុល ពត, តា ម៉ុកអីមកជិតទេ ។

ធានី : អត់មានសោះ ហើយយើងគ្រប់គ្រងតែគ្នាយើង ការពារតាមនឹងទៅ?

គូន :	បាទ! ហ្នឹងការពារព្រំដែន ។

ធានី :	ចឹងអ៊ំ ម៉េចបានអ៊ំដឹងច្បាស់ម៉េច ថា តា ម៉ុក នៅឆ្នាំ៨១?

គូន :	ចុះឃើញគាត់មកពេលដឹកអង្ករ ដឹកអីមកចែក ។ ហើយបាត់ តា សឿន បាត់អីទៅអស់ ឃើញ តា ម៉ុក មកដល់ ។

ធានី :	ចឹង តា សឿន នឹងបាត់ខ្លួនហើយ?

គូន :	បាទ! មិនដឹងជាគេដកទៅខាងណា តា សឿន, និង តា វ៉េត មិនដឹងគេដកទៅខាងណា ។

ធានី :	ដកទាំងពីរនាក់ម៉ង?

គូន :	បាទ!

ធានី :	ចឹង តា សឿន, តា វ៉េត បាត់ខ្លួនទាំងពីរនាក់?

គូន :	បាទ!

ធានី :	នៅឆ្នាំ៨១ ពេល តា ម៉ុក មក?

គូន :	បាទ!

ធានី :	ហើយចឹងទ័ពយើងរំលាយហើយ លែងវ៉ៃទៀតហើយ?

គូន :	វ៉ៃ ។

ធានី :	នៅវ៉ៃទៀត?

គូន :	បាទ!

ធានី :	មនសិការខ្ពស់ណាស់អ៊ំ?

គូន :	នៅតែវ៉ៃយួនទៀត បាទ! ។

ធានី :	ហើយកាលនឹងអ៊ំមានចិត្តម៉េចដែរ ម៉េចបាននៅព្យាយាមវ៉ៃការពារ?

គូន :	ទេ! គេថាយួនអាករធានគ្នោត បេះតែខំ ។

ធានី :	បេះខំ អត់មានគិតថារត់មកស្រុកអី?

គូន :	អត់ ។

ធានី :	ខ្លាចដែរ?

គូន :	បាទ!

ធានី :	ហើយដល់ពេល តា ម៉ុក គាត់មកដល់គាត់ធ្វើអីខ្លះ? អ៊ំមកដល់ឃើញតាម៉ុក គាត់រូបរាងយ៉ាងមេច ហើយគាត់ធ្វើអីខ្លះ?

គូន :	អត់ទេ អត់មានឃើញធ្វើអី ឃើញគាត់មេធំ គាត់ដឹកអង្ករដឹកអីឲ្យហូប ។

ធានី :	ម៉េចបានយើងដឹងថា តា ម៉ុក នឹងមេធំ?

គួន ៖ ហ៉ឺ! ពួកគេហៅ តា ម៉ុកៗ ប៉ុនមកបង្រៀនសាលានយោបាយ ។

ធានី ៖ បង្រៀនអីដែរ?

គួន ៖ ខ្ញុំមិនដែលបានចូលរៀនទេ ។

ធាន់ ៖ តា ម៉ុក នឹងបង្រៀននយោបាយទៅណាគេ?

គួន ៖ តា ម៉ុក, នួន ជា ក្នាគេ ។

ធានី ៖ ចឹងមាន នួន ជា មកដែរ?

គួន ៖ មក នួន ជា អ្នកសាលានយោបាយ ។

ធានី ៖ នៅឆ្នាំ៨១នឹង?

គួន ៖ ទេ! ឡើង៨៣ បានគាត់បង្រៀន ។

ធានី ៖ នួន ជា បង្រៀន ៨៣ ។ ចឹង៨១ តា ម៉ុក គាត់អញ្ជើញមកនឹង គឺមកចែកតែអង្ករ ខោ ចែកអាហារហូប?

គួន ៖ បាទ! អង្ករ ខោអាវ សម្ភារៈ ។

ធានី ៖ តែគាត់មានបង្រៀន គាត់មានប្រជុំ ឬប្រាប់យើងរឿងអីទេ?

គួន ៖ ខ្ញុំ យុទ្ធជន គេដែលហៅទៅបង្រៀន ។

ធានី ៖ តែឃើញ តា ម៉ុក មកចែកផ្ទាល់ដល់អ៊ំ?

គួន ៖ បាទ!

ធានី ៖ ចែកអង្ករចែកអីឲ្យអ៊ំផ្ទាល់?

គួន ៖ ចែក តាមមេ ខ្ញុំយកតាមក្រោមទៀត ។

ធានី ៖ ចះម៉េចបានអ៊ំដឹងថាគាត់នឹង តា ម៉ុកៗ?

គួន ៖ ចុះពួកគេហៅ តា ម៉ុកៗ ។

ធានី ៖ ហើយរូបរាងគាត់តយ៉ាងម៉េច កាលពេលអ៊ំឃើញដំបូង?

គួន ៖ គាត់ស្លៀកខោអាវខ្មៅ មួកស្លឹកត្នោត ។

ធានី ៖ រូងរាងគាត់?

គួន ៖ ខ្ញុំទៅមិនឃើញនិយាយស្តីទេ ។

ធានី ៖ រូបរាងគាត់ម៉េចទៅ មុខមាត់គាត់អី?

គួន ៖ មិនសូវហ៊ានមើលមុខដងកាលនោះ ។

ធានី ៖ ខ្ពស់ ហើយទាបអ៊ំកាលនោះ?

គួន ៖ ទេ! មិនជាខ្ពស់ប៉ុន្មានទេ ។

ធានី ៖ ចុះសំបុរគាត់ម៉េចដែរ?

គួន ៖ សំបុរសណ្តែកបាយ ។

ធានី ៖ សម្តីសំដៅគាត់ម៉េចដែរ?

គួន ៖ ទេ! ដែលខ្ញុំជួបនោះសម្តី ធម្មតាទេ ។

ធានី ៖ គាត់និយាយអីគេ កាលនឹង?

គួន ៖ ពេលដែលកាលនោះ គាត់ទៅបង្រៀនជះខ្វះ ឯលិច គេហៅជប់ត្រាង១ ខាងលិច៨០៨

ធានី ៖ ឆ្នាំប៉ុន្មានដែលគាត់ទៅបង្រៀន ដែលអីបានឃើញ?

គួន ៖ ដែលចាំបានទេ ។

ធានី ៖ ទៅបង្រៀនអីគេ?

គួន ៖ បង្រៀនខាងនយោបាយ ។

ធានី ៖ ខាងលិច៨០៨?

គួន ៖ បាទ!

ធានី ៖ ៨០៨ រាល់ថ្ងៃនឹងគេហៅភូមិអីគេ?

គួន ៖ ៨០៨នៅសព្វថ្ងៃ ។

ធានី ៖ គេហៅភូមិ៨០៨ដែរ?

គួន ៖ បាទ! នៅលើភ្នំ ។

ធានី ៖ កាលនឹងនៅឆ្នាំ៨១នឹង?

គួន ៖ បាទ!

ធានី ៖ ហើយកាលនឹងដល់ពេល តា សឿន, តា រ៉េត ទៅ តា ម៉ុក គាត់ឡើងមកគ្រប់គ្រងទ័ព អ៊ំ ជំនួសវិញ?

គួន ៖ បាទ!

ធានី ៖ យ៉ាងម៉េចទៀតទៅ ពេលទៅដល់ តា ម៉ុក គ្រប់គ្រងម្តង?

គួន ៖ ទេ! អត់មាន ធម្មតា ។

ធានី ៖ ហើយអ៊ំនៅតែវ៉ៃ បន្តវ៉ៃជាមួយវៀតណាម?

គួន ៖ នៅតែវ៉ៃៗវៀតណាមតទៅមុខ ។

ធានី ៖ ដល់ពេល៨១ យួនឡើងវ៉ៃទៀត?

គួន ៖ បាទ!

ធានី ៖ ហើយអ៊ំមានទិសខាងណាទ័ពអ៊ំ?

គួន :	ខ្ញុំនៅតែមុខនេះដែរ នៅមួយដួរវ៉ារិនចូលទៅខាងក្នុង ។

ធានី :	ទ័ពយើងវើយ៉ាងម៉េច?

គួន :	ចូលទៅវើខាងក្នុង វើមួយដួរវ៉ារិន ឫស្សី ស្វាយស អន្លុងរជុំ ។

ធានី :	ទៅខាងនឹងវិញ ហើយមានឈានទៅលេងផ្ទះទេ?

គួន :	អត់ទេ អត់ហ៊ានចូល ។

ធានី :	មេចចឹង នៅក្បែរគ្នានឹង?

គួន :	អត់ហ៊ានចូល ខ្លាច ។

ធានី :	ខ្លាចអីគេ?

គួន :	ខ្លាចយួន ខ្លាចវៀតណាម ។

ធានី :	ហើយកាលនឹងនឹកឪពុកម្ដាយ?

គួន :	នឹកដែរតើ អត់ចូល ។

ធានី :	ខ្លាចយួនយ៉ាងម៉េច?

គួន :	ខ្លាចយួនអាករ តែចាប់បានយើងទាហានដូចគ្នា ចាប់បាន ។

ធានី :	តែអ៊ីដែលពូគេនិយាយផ្ទាល់តែចៀកទេ ថាយួនអាករអីចឹង?

គួន :	បាទ! ពូថាយួនអាករ ។

ធានី :	អ្នកណាគេអ្នកប្រាប់?

គួន :	ហ៎! ពូតាមពាក្យសេកពាក្យសត្វ ក្រែវទៅយួនអាករៗ ។

ធានី :	ហើយដល់ពេលនៅឆ្នាំ៧១ តា ម៉ុក ហើយអ៊ីវើដល់ឆ្នាំប៉ុន្មាន បានអ៊ីនៅ?

គួន :	ខ្ញុំទើបនឹងសម្រាកនឹងចប់ ។

ធានី :	ចប់ឥឡូវពេលសមារណកម្មនេះ?

គួន :	បាទ!

ធានី :	ហើយអ៊ីធ្វើទ័ពនឹង នៅក្នុងកងពលអីកាលនឹង?

គួន :	កងពល១២ ។

ធានី :	កងពល១២ អ្នកណាគេអ្នកគ្រប់គ្រង?

គួន :	ពូ គង់ ។

ធានី :	ហើយភូមិអ៊ី កន្លែងកងពលនឹងនៅកន្លែងណាទៅ?

គួន :	គង់ នៅកងប៊ីញសព្វថ្ងៃនឹង ។

ធានី :	តា គង់ នឹងគាត់នៅរស់ទេ រាល់ថ្ងៃ?

គួន ៖ នៅ ។

ធានី ៖ គាត់ឈ្មោះអីគេ គង់?

គួន ៖ មិនដឹងអីគេ គង់ គាត់ ប៉ុនដឹងថា គង់ ។

ធានី ៖ ហើយ តា គង់ នឹង ប្រពន្ធគាត់ឈ្មោះអីគេ?

គួន ៖ ប្រពន្ធស្លាប់ទៅហើយ មិនដឹងឈ្មោះអីគេ ។

ធានី ៖ រកទឹកមើលលោកតា?

គួន ៖ រកទឹកអត់ឃើញ ។

ធានី ៖ ចុះគាត់ធ្វើអីគេរាល់ថ្ងៃ?

គួន ៖ សព្វថ្ងៃសម្រាកហើយ ដូចថាធ្វើការ ផ្កាយមួយ តា គង់ ។

ធានី ៖ ផ្កាយមួយ រាល់ថ្ងៃ តែគាត់អត់ធ្វើអីទេ គាត់នៅផ្ទះ?

គួន ៖ ធ្វើទាហានដែរ នៅទាហាន ។

ធានី ៖ តែគាត់នៅផ្ទះទេ?

គួន ៖ បាទ! មិនដឹងដែរ ។

ធានី ៖ ផ្ទះគាត់នៅខាងណា?

គួន ៖ នៅទល់អែបផ្ទះមេឃុំ ។

ធានី ៖ អែបផ្ទះមេឃុំ?

គួន ៖ បាទ! នៅខាងជើងផ្ទះមេឃុំ ។

ធានី ៖ ខាងជើងផ្ទះមេឃុំ ជាប់ផ្ទះមីង ភាព ទេ?

គួន ៖ ទេ! ជាប់ផ្ទះ តា រាស្រ្ត ។

ធានី ៖ តា រាស្រ្ត?

គួន ៖ បាទ! នៅខាងជើងផ្លូវ ។

ធានី ៖ កន្លែងផ្ទះ តា រាស្រ្ត កន្លែងផ្ទះដែលមាតារាងបាល់នឹង?

គួន ៖ ទេ! អានោះ តា ភា ។

ធានី ៖ តា រាស្រ្ត មកខាងណាវិញ?

គួន ៖ មកនេះ មកជិតកន្លែងឡាន ជិតសាលារៀនកុមារ ។

ធានី ៖ ផ្ទះ តា គង់ នឹងខាងណាសាលារៀន?

គួន ៖ ខាងជើងផ្ទះ តា រាស្រ្ត ។

ធានី ៖ តា រាស្រ្ត នឹងត្រកូលគាត់អីរាស្រ្ត?

គួន ៖ អត់ស្គាល់ទេ ។

ធានី ៖ តែគាត់មេឃុំ?

គួន ៖ បាទ!

ធានី ៖ ខាងជើងផ្ទះមេឃុំនោះ?

គួន ៖ បាទ!

ធាន់ ៖ តែជាប់គ្នាទេ ផ្ទះរបង?

គួន ៖ ម្ខាងផ្លូវម្នាក់ ។

ធានី ៖ តែផ្ទះគាត់អត់ជាប់សាលារៀនទេ?

គួន ៖ អត់ទេ ។

ធានី ៖ ហើយលោកតានៅក្រោមការគ្រប់គ្រងរបស់ តា គង់ នឹងរហូត?

គួន ៖ រហូតទល់ចប់ ។

ធានី ៖ ចឹងលោកតា អាចជួយរៀបរាប់បានទេ ថាពី?

គួន ៖ ដែលរៀបបានទេ ។

ធានី ៖ ចង់សួរថា ពី៨១មក លោកតាធ្វើទាហាននឹងទៅវ៉ៃទៅ លោកតាមិនប្រាប់ថាទៅខាងវ៉ារិន ទៅខាងអីនឹង បន្ទាប់ពីនឹងមកទៅវ៉ៃនៅកន្លែងណាទៀត ហើយវៀតណាមវ៉ៃធ្វើម៉េចបាន យើងចូលដល់អន្លង់វែងយើង ធ្វើម៉េចបានយើងមកដល់អន្លង់វែង ហើយយើងត្រឡប់ទៅ វិញ ម៉េចទៀតទៅ ចង់និយាយចឹង?

គួន ៖ យ៉ាប់ ។

ធានី ៖ យ៉ាប់រៀប ចឹងសួរវិញ ។ បន្ទាប់ពី៨១លោកតារៀបវ៉ៃនៅនឹងទៀត ។ ដល់ពេល៨២ លោកតាវ៉ៃណាវិញ?

គួន ៖ នៅទៅវ៉ៃអន្លុងជុំ ។

ធានី ៖ ដល់ពេល៨៣?

គួន ៖ ៨៣ទៅនៅនោះ ។

ធានី ៖ ៨៤?

គួន ៖ នៅនោះ ។

ធានី ៖ ដល់ពេល៨៥?

គួន ៖ ៨៥ មើល៧៩ នៅទៅនោះធ្វើការតែនោះ ។

ធានី ៖ ធ្វើការតែនោះរហូត?

គួន ៖ បាទ!

ធានី ៖ ចឹងយើងអត់ដែលបានមកអន្លង់វែងចឹង?

គួន ៖ អត់ដែលបានមកទេ ។

ធានី ៖ ចុះពេលណាយើងចុះ?

គួន ៖ មកពេលម្តងៗ មកពេលបើកសម្ភារៈខោអាវអីមក ។

ធានី ៖ ចឹងបានន័យថាអន្លង់វែងទ័ពយើងចូលដល់វិញ?

គួន ៖ បាទ!

ធានី ៖ ពេលណាដែលទ័ពយើងបានវ៉ៃគ្រប់គ្រង?

គួន ៖ កាលដែលយើងវ៉ៃដាច់អាច្រកជាំនេះទៅ បានវៀតណាមរត់ទៅ បានយើងវ៉ៃដាច់អន្លង់វែង ។

ធានី ៖ ឆ្នាំប៉ុន្មានអីនោះ ដែលវៀតណាមរត់ទៅវិញ?

គួន ៖ ប៉ុន្មានទេ ភ្លេចហើយ ។

ធានី ៖ រកនឹកមើល ៧៩អីនៅវ៉ៃរហូត ដល់៧៥នៅដែរ ដល់ពេល៧០ប៉ុន្មាន?

គួន ៖ ៧៨ ហ៎!

ធានី ៖ ៨០ហើយ?

គួន ៖ អាច៨២ ៨៣ ។

ធានី ៖ ៨២ ៨៣ យើងចុះមកអន្លង់វែងនឹងវិញ?

គួន ៖ បាទ!

ធានី ៖ ហើយយើងបានធ្វើទីតាំងនៅនឹងរហូត?

គួន ៖ បាទ! នៅរត់ៗតែចុះ នៅមកវៀតណាមមកក៏រត់ឡើងទៅលើ ។

ធានី ៖ ហើយដល់ពេលណាក៏យើងបាន?

គួន ៖ យើងវ៉ៃដេញឈ្នះទៅក៏មកនៅវិញ ។

ធានី ៖ ឆ្នាំប៉ុន្មាន អីដែលវ៉ៃដេញឈ្នះ?

គួន ៖ អូ! អត់ដែលចាំបានទេ ។

ធានី ៖ រកនឹកមើលអី?

គួន ៖ រកនឹកចុះឡើងៗ ។

ធានី ៖ កាលនឹងប្រជាជនយើងចុះពីលើភ្នំនៅ?

គួន ៖ អឺ!

ធានី ៖ ចុះតាមណា តាមផ្លូវ?

គួន ៖ ចុះតាមផ្លូវយើង ។

ធានី ៖ មានផ្លូវដែរ ក្រែងអ៊ំថាអត់មានផ្លូវផង?

គួន ៖ ផ្លូវ តា ម៉ុក ឈូស ។

ធានី ៖ តា ម៉ុក ឈូស?

គួន ៖ បាទ!

ធានី ៖ ចឹងផ្លូវនឹងកាលមុនអត់មានទេ?

គួន ៖ អត់មានទេ ។

ធានី ៖ អត់មានផ្លូវរទេះគោ ផ្លូវអីក៏អត់ដែរ?

គួន ៖ អត់ ។

ធានី ៖ ទទេរស្អាត?

គួន ៖ បាទ!

ធានី ៖ ហើយ តា ម៉ុក ឈូសពីលើភ្នំចុះមក?

គួន ៖ តា ម៉ុក ឈូស ចុះ ។

ធានី ៖ ម៉េចបានឈូសកើតអ៊ំ យើងមានអីធ្វើ?

គួន ៖ ដែរអត់ ម៉ៃខូ ។

ធានី ៖ ម៉ៃខូ មកពីណាវិញ?

គួន ៖ ឡានអាត្រាក់មកកត្រឹក ។

ធានី ៖ មកពីណាវិញ?

គួន ៖ គេយកមកពីថៃ ។

ធានី ៖ ចឹងអ្នកណាគេអ្នកធ្វើផ្លូវនឹងឲ្យ តា ម៉ុក អ្នក?

គួន ៖ តា ម៉ុក អ្នកធ្វើ ។

ធានី ៖ តា ម៉ុក គាត់អ្នកធ្វើខ្លួនឯង?

គួន ៖ បាទ!

ធានី ៖ គាត់អ្នកបញ្ជាគេឲ្យធ្វើ ឬក៏គាត់មក?

គួន ៖ បាទ! បញ្ជាគេ ។ ហើយ តា ម៉ុក ដែលគាត់កំបុតជើងនេះ មកពីគាត់ធ្វើផ្លូវ ។

ធានី ៖ ធ្វើផ្លូវនឹងដែរ?

គួន ៖ បាទ!

ធានី ៖ អាផ្លូវយើងចុះនឹង ឬអាផ្លូវក្រោមនេះ?

គួន ៖ អាផ្លូវនោះទេ ។

ធានី ៖ ផ្លូវណា?

គួន ៖ ផ្លូវ៨០៨ ។

ធានី ៖ ផ្លូវលើភ្នំនឹង?

គួន ៖ ផ្លូវលើភ្នំ ។

ធានី ៖ ដោយសារអីគេបានជាទៅជាកំបុតជើង?

គួន ៖ ផ្ទុះមីនៗអាគ្រាក់នឹងប៉ះដល់ តា ម៉ុក គាត់ឈរបញ្ជាគេឲ្យគេឈូស ។

ធានី ៖ ហើយអាគ្រាក់នឹង កិនមីន?

គួន ៖ បាទ!

ធានី ៖ មីននឹងមីនអីគេ?

គួន ៖ មីនគោន ។

ធានី ៖ ហើយអ្នកណាគេអ្នកដាក់?

គួន ៖ ទេ! អត់ដឹងរឿងអ្នកណាគេដាក់ ។

ធានី ៖ ដឹងតែផ្ទុះមីន?

គួន ៖ បាទ!

ធានី ៖ មិនមែនយើងអ្នកដាក់?

គួន ៖ អត់ទេ គាត់ផ្ទុះខ្លួនឯង ។

ធានី ៖ អ៊ំបានដឹងរឿងហេតុការណ៍ តា ម៉ុក ផ្ទុះមីននឹងដែរ?

គួន ៖ ទេ! ឮតែថាផ្ទុះខ្ញុំនៅក្នុង ។

ធានី ៖ អ៊ំនៅក្នុង អ! នៅវ៉ារិន ។ ហើយដល់ពេលចុះមកក្រោម ចុះឆ្នាំណា អត់ចាំទេ ដែល តា ម៉ុក គាត់ចាប់ផ្ដើមឈូសហើយ ឲ្យប្រជាជនយើងចុះពីលើភ្នំនឹង?

គួន ៖ ដែរចាំទេ ។

ធានី ៖ អត់ចាំទេ? ហើយអ៊ំនៅពេលណា ដែលអ៊ំមកដលនេះវិញ?

គួន ៖ កាលនឹងវ៉ៃឈ្នះអន្លង់វែងបានមកនៅនេះ ។

ធានី ៖ មកនៅលំទងនេះ?

គួន ៖ បាទ!

ធានី ៖ វ៉ៃឈ្នះអន្លង់វែង ចឹងអ៊ំលែងទៅវ៉ារិនហើយ?

គួន : ទេ! ទៅនៅតែទៅៗធ្វើការ ។

ធានី : ប៉ុន្តែគ្រួសារអ៊ំនៅនេះ?

គួន : បាទ!

ធានី : ចឹងអ៊ំរៀបគ្រួសារឆ្នាំប៉ុន្មាន?

គួន : ខ្ញុំគ្រួសារខ្ញុំបាន ហ៉េ!គ្រួសារបាន៧៩ ។

ធានី : ១៩៧៩ រៀបគ្រួសារនៅណាវិញ?

គួន : គេរៀបឲ្យនៅលើខ្នងភ្នំ នៅជប់សម្លឆ្ងាញ់ ។

ធានី : ដែលថានៅជប់គគីរនឹង?

គួន : នៅជប់សម្លឆ្ងាញ់ ។

ធានី : នៅខាងណាវិញ?

គួន : ខាងលិច៨០៨ ។

ធានី : បើសព្វថ្ងៃគេហៅអីគេ?

គួន : សព្វថ្ងៃអត់មានអីទេ គេហៅអូរសម្លឆ្ងាញ់ វាអស់មានភូមិនៅលើខ្នង ។

ធានី : ហើយម៉េចបានស្គាល់គ្រួសារអ៊ំ?

គួន : គេនៅដឹកជញ្ជូន ។

ធានី : ចឹងគាត់នៅដឹកជញ្ជូន អ៊ំរៀបការជាមួយគាត់នៅ៧៩ ។ ចឹងគាត់នៅលើភ្នំ អ៊ំចុះមកវិញខាងក្រោម?

គួន : បាទ!

ធានី : នៅដល់ពេល តា ម៉ុក ឈូសផ្លូវហើយ គាត់ចុះមកក្រោមដែរ?

គួន : បាទ!

ធានី : អ៊ំចុះមកមុនគាត់?

គួន : ខ្ញុំចុះទៅធ្វើការនៅឯក្នុង ។

ធានី : ចឹងដល់ពេលគាត់ចុះមកមានអីកន្លែងណាស្នាក់នៅ?

គួន : មកនៅតាមលំនង អន្លង់វែង ។

ធានី : គ្រួសារអ៊ំ?

គួន : ខ្ញុំៗនៅលំនង ។

ធានី : នៅលំនងចាស់យើងនឹង?

គួន : ហ្នឹងហើយ ។

ធានី ៖ ចឹងនៅពេលដែល តា ម៉ុក ឈូសផ្លូវចុះមកនឹង វ៉ៃឈ្នះនឹង អ៊ំរកនឹកមើលឆ្នាំបន្ទាន?

គួន ៖ ឆ្នាំប៉ុន្មានទេ ។

ធានី ៖ កាលនឹងអ៊ុនគាត់ចូលនៅ?

គួន ៖ ចូលហើយ ។

ធានី ៖ អ៊ុនគាត់ចូលហើយបាន តា ម៉ុក ឈូសផ្លូវចុះមកនឹង?

គួន ៖ បាទ! ហ្នឹង ។

ធានី ៖ អា៩០ ៩១?

គួន ៖ វាប៉ុននោះឯង ។

ធានី ៖ រកនឹកមើល ៩០ ឬ៩១?

គួន ៖ ៩១ ។

ធានី ៖ ៩១ អ៊ុនគាត់ចូលមកដល់មុន ឬយើងមកដល់មុនអ៊ុនគាត់?

គួន ៖ ហ៎! យើងមកដល់មុន ។

ធានី ៖ ចឹងពេលដែល តា ម៉ុក ឈូសផ្លូវនឹងទើបបានដាច់ជើងគាត់?

គួន ៖ បាទ!

ធានី ៖ ចឹងគាត់ដាច់ជើង៩១ដែរ?

គួន ៖ បាទ!

ធានី ៖ ហើយគ្រួសារអ៊ំចុះមក៩១ដែរ?

គួន ៖ បាទ!

ធានី ៖ ចុះពីលើភ្នំមកនៅលំទង?

គួន ៖ បាទ!

ធានី ៖ កាលនឹងម៉េចបានគាត់មកនៅលទងកើត អ្នកណាអ្នកចាត់តាំងឲ្យមកនៅនឹង?

គួន ៖ តា ម៉ុក អ្នកចែកកម្លាំងឲ្យ ។

ធានី ៖ ចឹងកងពលអ៊ំ កងពល១២ត្រូវនៅលំទង?

គួន ៖ បាទ!

ធានី ៖ កាលនឹងគេហៅលំទងចឹង?

គួន ៖ បាទ!

ធានី ៖ ចឹងឲ្យតែមានគ្រួសារដែលធ្វើការដូចអ៊ំចឹង ត្រូវមកនៅលំទងទាំងអស់គ្នា?

គួន ៖ បាទ! ប្រជាជនអ្នកស្រុក ។

ផានី ៖ ទាំងអស់គ្នា?

គួន ៖ និយាយរួមអ្នកនៅលើខ្នងគេច្រើនទាហានទាំងអស់ ។

ផានី ៖ ចង់និយាយថាជាទូទៅ អ្នករស់នឹងបែកតាមកង ចុះអ៊ំអាចចាំបានទេថា ដូចកងពលលេខ ១២របស់អ៊ំនឹងនៅលំទង ចុះកងពលផ្សេងៗទៀត?

គួន ៖ នៅទៅផ្អាវ នៅទៅ(ស្តាប់មិនបាន) ។

ផានី ៖ អ៊ំចាំឈ្មោះទេ?

គួន ៖ អត់ចាំបានទេ ។

ផានី ៖ គ្រាន់ដឹងថាទៅផ្អាវ ទៅភូមិចាស់ៗដែលមានពីមុននឹង?

គួន ៖ អឺ! ចាំតែកងពល ។

ផានី ៖ កាលនឹងអ្នកណាអ្នកចាត់ចែងឲ្យទៅនៅចឹង?

គួន ៖ តា ម៉ុក ។

ផានី ៖ ម៉េច តា ម៉ុក គាត់ដឹងថា ភូមិរស់នឹងជាភូមិចាស់?

គួន ៖ ដែលអត់ដែនទីគាត់ ។

ផានី ៖ មានដែនទីទៀត?

គួន ៖ អឺ!

ផានី ៖ ដែនទីអ្នកណាគូរឲ្យ?

គួន ៖ ទេ! មិនដឹងរឿង ។

ផានី ៖ ចឹងគ្រួសារអ៊ំចុះមុន ពេលនឹងអ៊ំអត់បានមកជាមួយគាត់ទេ?

គួន ៖ អត់ ។

ផានី ៖ អ៊ំនៅខាងក្នុង?

គួន ៖ បាទ!

ផានី ៖ ចឹងធ្វើម៉េចបានអ៊ំដឹងថា គ្រួសារអ៊ំនៅលំទង?

គួន ៖ គេប្រាប់ ថាមកនៅលំទង ពេលយើងមួយឆ្នាំនេះសុំគេមកលេងឯស្រុកក្រៅបានម្តង ។

ផានី ៖ មួយឆ្នាំលេងម្តង?

គួន ៖ មួយឆ្នាំត្រូវគេឲ្យឡើងបើកខោអាវសម្ភារៈ ។

ផានី ៖ ហើយមកលេងបានប៉ុន្មានថ្ងៃបានទៅវិញ?

គួន ៖ ១១ថ្ងៃ ។

ផានី ៖ កាលនឹងគ្រួសារអ៊ំបានកូនប៉ុន្មានហើយ?

កូន ៖ កូនមួយ ។

ធានី ៖ កូនស្រីកូនប្រុស?

កូន ៖ ស្រី ។

ធានី ៖ កូនស្រីមួយកូនច្បងគេនឹង?

កូន ៖ បង ។

ធានី ៖ ដល់ពេលហើយម៉េចទៀតទៅ?

កូន ៖ យ៉េងវៃចាញ់គេទៅ អាអ្នកនៅនេះរត់ឡើងទៅលើ១-២-៣សារទៅបានមកនៅជាប់ វៃចាញ់វៀតណាម ចាញ់ទាហានខ្មែរ រត់ឡើងទៅលើ ។

ធានី ៖ ពេលណា?

កូន ៖ យើងមកនៅលំទង បានមួយឆ្នាំវៃគា ។

ធានី ៖ វៃគ្នាទៀត?

កូន ៖ វៃចាញ់គេរត់ឡើងលើ ។

ធានី ៖ ហើយពេលណាបានចុះមកវិញ?

កូន ៖ ទៅនៅ៣-៤ខែ ចុះមកវិញ ។

ធានី ៖ ចុះកាលនឹងផ្លូវអីយើងធ្វើហើយអស់ហើយ?

កូន ៖ បាទ! ផ្លូវធ្វើហើយ ។

ធានី ៖ ចឹង៩១មក តា ម៉ុក ឈូសពីលើភ្នំដេញចុះក្រោមរហូត ។

កូន ៖ បាទ!

ធានី ៖ ចុះស្ពានយើងនោះ?

កូន ៖ ស្ពានទើបនឹងធ្វើក្រោយ ពីដើមនៅតែអាទំនប់លើស្ពាន ឆ្លងតាមនេះ ។

ធានី ៖ ហៅទំនប់អីគេ?

កូន ៖ ទំនប តា ម៉ុក ខាងលើស្ពាន ។

ធានី ៖ ចុះក្រែងជាកន្លែងផ្ទះ តា ម៉ុក រាល់ថ្ងៃនឹង កាលមុនមិនកូនកោះ កូនភ្នំ ចុះសុទ្ធតែពស់ សុទ្ធតែអីធ្វើម៉េចនៅកើតទៅ?

កូន ៖ ចេះតែនៅ កាយថ្មយកមកចាក់បំពេញបានកើតទំនប់ កាយថ្មនៅនឹងស្ពាន ឃើញថ្មនៅនឹងស្ពាន ថ្មកូនភ្នំនឹង ។

ធានី ៖ ចឹងយើងនៅនឹងកូនភ្នំនឹងដែរ?

កូន ៖ ទេ! នៅតែគាត់ តា ម៉ុក ។

ធានី :	អ៊ំដឹងរឿងនឹងទេ រឿងផ្ទះ តា ម៉ុក?

គួន :	ទេ! អត់ដឹងរឿងទេ ។

ធានី :	ដឹងថាគេធ្វើម៉េច កសាងម៉េច?

គួន :	អត់ដឹងម៉េច ។

ធានី :	ហើយចឹងអ៊ំដឹងថាផ្ទះនឹងមានអីខ្លះ?

គួន :	ទេ! អត់ដឹងថាមានអី ។

ធានី :	តែអ៊ំធ្លាប់ ដែលចូល?

គួន :	ប៉ុនចូលទៅ ដូចមនដែលឃើញមានអី ឃើញតែស្វាយ ។

ធានី :	ចុះដែលអ៊ំនៅធ្លាបទៅចូលនៅក្នុងនឹងដែរ កាលពេលនៅធ្វើយោធា?

គួន :	ចូលដែលប៉ុនមិនដែលទៅឃើញមានអី ។

ធានី :	កាលនឹងអ៊ំចូលទៅធ្វើអីគេ?

គួន :	ទេ! ចូលទៅលេង ចូលទៅម្តងៗ ។

ធានី :	ចូលទៅលេង តា ម៉ុក ឲ្យចូលលេងដែរ?

គួន :	ចូលទៅនឹង ចូលទៅគៀនៗ ដើរមើលកូនភ្នំ ទៅវាស្រឡះ នៅដើមឈើធំមួយ ប៉ុន យាង តា ម៉ុក ឲ្យអារធ្វើផ្ទះ ។

ធានី :	ដើមយាងនៅមុំផ្ទះនឹង?

គួន :	បាទ! អារធ្វើស្រឡះ ។

ធានី :	អ៊ំអត់ដងថា តា ម៉ុក ធ្វើផ្ទះនឹងដើម្បីអី?

គួន :	អត់ដឹងទេ ។

ធានី :	ហើយចុះស្ពានអូរជីករាល់ថ្ងៃនឹង គេធ្វើដើម្បីអី?

គួន :	អត់ដឹងដែរ ប៉នធ្វើឲ្យឆ្លងៗ ។

ធានី :	ចុះអ៊ំដឹងថា តា ម៉ុក បានកសាងអីខ្លះនៅអន្លង់វែងយើងនេះ?

គួន :	ថ្នល់ ប្រឡាយៗ ។

ធានី :	ហើយអីទៀត?

គួន :	ថ្នល់ហើយអាទំនប់ៗយើងក្រោម ។

ធានី :	ទំនប់អីគេ?

គួន :	ទំនប់កល់ថ្មនេះ ។

ធានី :	ទំនប់ថ្មីយើងរាល់ថ្ងៃនេះ?

កូន ៖ គេហៅទំនប់ថ្មីៗ ។

ធានី ៖ រាល់ថ្ងៃនេះ តែកាលមុនគេហៅទំនប់កល់ថ្ម?

កូន ៖ អានោះគេហៅទំនប់កល់ថ្ម ។

ធានី ៖ កាលសម័យ តា ម៉ុក គេហៅទំនប់កល់ថ្ម?

កូន ៖ បាទ!

ធានី ៖ ទើបឥឡូវទេ គេដូរដាក់ទំនប់ថ្មី?

កូន ៖ បាទ!

ធានី ៖ ចឹងអ៊ំមួយឆ្នាំមកលេងគ្រួសារម្តង ហើយទៅវាំរិនរហូត?

កូន ៖ បាទ!

ធានី ៖ ចុះអ៊ំមានដឹងរឿងដែលគេវ៉ៃ រត់ចុះរតឡើងដឹងរឿងនឹងទេ?

កូន ៖ អត់ទេ ។

ធានី ៖ ចុះអ៊ំនិយាយមិញនោះ?

កូន ៖ អូ! ដែលគេវ៉ៃក្រោយដឹងដែរ ប៉ុនខ្ញុំនៅធ្វើការមុខៗ ។

ធានី ៖ ចុះគ្រួសារអ៊ំ?

កូន ៖ គ្រួសារគេរត់ឡើងទៅលើ ចុះដែលមានអី ដែលមានរទេះមានឡានអី មានវ៉ាឡូមួយនឹង អន្តរទៅលើគេបើកឲ្យស៊ីលើ ។

ធានី ៖ អ៊ំអត់បារម្ភអីកាលនឹង?

កូន ៖ អត់ ។

ធានី ៖ ចុះគេវ៉ៃគ្នាចឹង មានអារម្មណ៍ម៉េចទៅ?

កូន ៖ ហ៊ើ! មានអារម្មណ៍ម៉េច មានតែគ្រួសារគេនៅនេះរត់ឡើងទៅលើ ។

ធានី ៖ អត់មានអារម្មណ៍គេវ៉ៃគ្នាទៀត ខ្មែរសោះ?

កូន ៖ វាមាន តែខ្មែរដូចគ្នា តែវ៉ៃទៅមិនដែលឃើញ ។ ពីមុនឃើញយៀកណាមមែន ដល់ចប់ មកឃើញតែខ្មែរដូចគ្នា ។

ធានី ៖ ចឹងអត់ចង់វ៉ៃទៀត?

កូន ៖ អានេះដូចគូរមុខដាក់គ្នា ។

ធានី ៖ តែអ៊ំដូចថានៅខាងក្នុងចឹង វ៉ៃដែល វ៉ៃឈ្លប?

កូន ៖ វ៉ៃធំ ។

ធានី ៖ តែវ៉ៃខ្មែរដូចគ្នានឹង?

គួន ៖ បាទ!

ធានី ៖ ហើយចឹងមានអារម្មណ៍ម៉េចទៅ ពេលវ៉ៃនឹង?

គួន ៖ មានអារម្មណ៍ថាម៉េច បើយើងមិនបាញ់គេ គេបាញ់យើង?

ធានី ៖ គិតចឹង?

គួន ៖ បាទ!

ធានី ៖ ពេលនឹង មិន តា ម៉ុក អ្នកគ្រប់គ្រងវិញ?

គួន ៖ បាទ!

ធានី ៖ ចឹង តា គង់ នឹងគាត់អ្នកដឹកនាំទៅវ៉ៃនៅខាងក្នុងនឹងទៅ?

គួន ៖ បាទ!

ធានី ៖ ចុះអ៊ំមានដែលស្គាល់ សុន សេន ហ៎?

គួន ៖ ទេ! ឮតែគេថា មិនដែលឃើញ ។

ធានី ៖ ចុះដែលដឹងថា សុន សេន ត្រូវសម្លាប់ទាំងគ្រួសារ?

គួន ៖ ឮតែគេថា សម្លាប់ ។

ធានី ៖ ឮគេថាម៉េចខ្លះ?

គួន ៖ ឮគេថា សម្លាប់កូនដាក់លើឈើ ។

ធានី ៖ ម៉េចទៅអ៊ំ សម្លាប់?

គួន ៖ ទេ! ឮគេថា សុន សេន ស្លាប់ៗ ។

ធានី ៖ ចុះអ៊ំមានដឹងរឿង តា ម៉ុក ហើយ តា ប៉ុល ពត ឈ្លោះគ្នាទេ?

គួន ៖ អត់ដឹងទេ ។

ធានី ៖ ហើយអ៊ំធ្លាប់ឃើញ តា នួន ជា ប៉ុន្តែដែលឃើញ តា ប៉ុល ពត ទេ?

គួន ៖ អត់ដែលឃើញមុនផង ។

ធានី ៖ ឃើញតែ តា នួន ជា?

គួន ៖ បាទ!

ធានី ៖ ចុះ តា ខៀវ សំផន?

គួន ៖ ខៀវ សំផន ក៏មិនដែលឃើញ ។

ធានី ៖ ឮឈ្មោះដែរ?

គួន ៖ គ្រាន់តែឮតែឈ្មោះ ។

ធានី ៖ ចុះអ្នកផ្សេងទៀតអី តា អៀង សារី?

គួន ៖ មិនដែលឃើញទេ ។

ធានី ៖ ចំពោះលោកតា ផ្ទាល់ដូចថារឿងរ៉ាវដែលលោកតាបាននិយាយមិញ គឺទាក់ទងនឹងព្រឹត្តិការណ៍ យើងវៃគ្នាឯងអីចឹង តើលោកតាគិតថារឿងរ៉ាវអស់នឹង យើងគួរតែបង្រៀនទៅដល់កូនចៅជំនាន់ក្រោយឲ្យបានដឹងរឿងអស់នឹងទេ?

គួន ៖ បាទ! ចុះ ។

ធានី ៖ ហេតុអីលោកតា គិតថាគួរតែបង្រៀនដល់កូនចៅក្រោយបានដឹង ថាយើងឈ្លោះគ្នាម៉េច?

គួន ៖ យើងឈ្លោះគ្នា វាខ្មែរដូចគ្នា យើងមិនត្រូវឈ្លោះគ្នា ។

ធានី ៖ ចង់បង្រៀនថា កុំឲ្យកេងក្រោយៗឈ្លោះគ្នាចឹង?

គួន ៖ បាទ! ហ្នឹងហើយ ។

ធានី ៖ ហើយវាមានប្រយោជន៍អីទៅ?

គួន ៖ អត់មានផលប្រយោជន៍ ខាត ។

ធានី ៖ ខាតទាំងសងខាង?

គួន ៖ ខាត បានថាខាតៗកម្លាំងខាងក្នុង ខាតកម្លាំងខាងនេះ ខាតទាំងអស់ ។

ធានី ៖ ចុះមកដល់រាល់ថ្ងៃនេះ លោកតាដែលធ្លាប់ឃើញមានគេឈ្លោះគ្នាចឹងទៀតទេ ហេតុការណ៍ចឹងៗ?

គួន ៖ អត់ទេ អត់ឃើញ ។

ធានី ៖ អត់មាន?

គួន ៖ បាទ!

ធានី ៖ នៅអន្លង់វែងយើងអត់ដែលមាន?

គួន ៖ បាទ!

ធានី ៖ ចុះឆ្នាំណាដែលលោកតាមកនៅភូមិយើងនេះម៉ង?

គួន ៖ ចុះមកសមាហរណកម្ម មកនៅនេះ ។

ធានី ៖ ចឹងលោកតាធ្វើសមាហរណកម្ម នៅណា នៅវ៉ារិន?

គួន ៖ ទេ! ធ្វើនៅអន្លង់វែងនេះឯង ។

ធានី ៖ ប៉ុន្តែកាលមុន មិនគ្រួសារលោកតានៅលើភ្នំ លោកតានៅវ៉ារិន?

គួន ៖ ខ្ញុំធ្វើការនៅនោះ គេហៅមកនេះ ។

ធានី ៖ គេហៅមកអន្លង់វែង?

គួន ៖ មក ។

ធានី ៖ ឆ្នាំប៉ុន្មាន ដែលគេហៅមកសមាហរណកម្ម?

គួន ៖ មិនបានទេ ។

ធានី ៖ កាលនឹងគេបោះឆ្នោត ហើយនៅ?

គួន ៖ ទៅនេះទៅនៅជិរំ បានគ្រួសារជម្លៀសទៅនៅជិរថៃ ។

ធានី ៖ ចុះលោកតា?

គួន ៖ បាន៧៩នេះបានចុះមកសមាហរណកម្ម ។

ធានី ៖ ៧៩អីទៀត ៩០ជាងហើយ ៩០ប៉ុន្មាន ៩៩?

គួន ៖ បាទ! ៩៩ ។

ធានី ៖ ចឹង៩៩ធ្វើសមាហរណកម្ម?

គួន ៖ បាទ!

ធានី ៖ គេហៅមកអន្លង់វែង ហៅលោកតា ទាំងកងពលទាំងអីមក ហើយទាំងគ្រួសារមកដែរ?

គួន ៖ បាទ!

ធានី ៖ ហើយមកគេថាម៉េចទៅ?

គួន ៖ កាលនោះ មិន តា ដាន់ គណៈស្រុកនេះគាត់ប្រតិកម្មម៉ាសារទៅ បានយើងចុះមកសមាហរណកម្ម ។

ធានី ៖ ដឹងរឿង តា ដាន់?

គួន ៖ តា ដាន់ គេផ្ដាច់ខ្លួនទៅក្នុង ។

ធានី ៖ ហើយមានអារម្មណ៍មេចទៅ?

គួន ៖ ហើយខ្ញុំ ប្រជុំគណៈស្រុកត្រពាំងប្រាសាទប្រាប់ថាកុំឲ្យរត់ឡើងទៅលើ ឲ្យរត់ទៅក្នុង ។

ធានី ៖ គេប្រជុំប្រាប់ឲ្យទៅក្នុង?

គួន ៖ ទេ! ប្រាប់តែខ្ញុំទេ ។

ធានី ៖ ប្រាប់តែអីទេ?

គួន ៖ ប្រជុំតែត្រូវគ្នាខ្ញុំ ។

ធានី ៖ តែអីបានរត់ទៅ?

គួន ៖ អត់ទេ ។

ធានី ៖ ម៉េចចឹង?

គួន ៖ ចុះបើគ្រួសារគេទៅនោះអស់ ។

ធានី ៖ ចឹងអ៊ំទៅណាវិញ?

កូន ៖ ទៅលើភ្នំ ។

ធានី ៖ ចឹងរត់ទៅជាមួយគ្រួសារដែរ?

កូន ៖ បាទ!

ធានី ៖ ចឹងខាងណាអ្នកមកប្រជុំប្រាប់?

កូន ៖ អត់មានប្រជុំទេ ។

ធានី ៖ ហ្នឹងហើយអ្នកដែលប្រាប់អ៊ំម្នាក់ឯងឈ្មោះអីទេ?

កូន ៖ តា ជុំ នៅត្រពាំងប្រាសាទ ។

ធានី ៖ តា ជុំ រាល់ថ្ងៃគាត់នៅត្រពាំងប្រាសាទ?

កូន ៖ ទេ! រាល់ថ្ងៃគាត់នៅខេត្ត ។

ធានី ៖ តា ជុំ នឹងឈ្មោះអីគេជុំ?

កូន ៖ អត់ដឹង ។

ធានី ៖ តា ជុំ ប្រពន្ធគាត់ឈ្មោះអីគេ?

កូន ៖ អត់ស្គាល់ ។

ធានី ៖ តែដឹងថា សព្វថ្ងៃ គាត់នៅខេត្ត?

កូន ៖ បាទ!

ធានី ៖ អត់ដឹងនៅភូមិឃុំអី?

កូន ៖ អត់ ។

ធានី ៖ ហើយគាត់នឹងមានងារជាអីគេ កាលនឹងបានប្រាប់អ៊ំ?

កូន ៖ ទេ! ធ្វើមេទាហាន ។

ធានី ៖ ចឹងកាលដំបូង ក្រែង តា គង់?

កូន ៖ តា គង់ ប៉ុនគេមេទាហាននៅខាងត្រពាំងប្រាសាទ ។

ធានី ៖ ហើយម៉េចបានអ៊ំស្គាល់គាត់?

កូន ៖ មករៀនៗទៅជួប ។

ធានី ៖ ហើយគាត់ប្រាប់ទៀត តិចទៀតមានគេរត់?

កូន ៖ ទៅប្រាប់ ។

ធានី ៖ គាត់ដឹងមុន?

កូន ៖ បាទ!

ធានី : ហើយដូចថាកាលពេលអ៊ំរត់ឡើងភ្នំនឹង ពេលនឹងអ៊ំនៅវ៉ារិនទេ?

កូន : បាទ!

ធានី : ចុះ តា ពក នោះ ក្រែងអ៊ំថា អ្នកគ្រប់គ្រងអ៊ំពីដំបូងមក?

កូន : តា ពក នៅក្រោមបញ្ជា តា មុ៉ក ។

ធានី : ដល់ពេល តា គង់ មកគ្រប់គ្រងកងពលនឹង តា ពក គាត់នៅពីលើ តា គង់ នឹងដែរ?

កូន : បាទ! នៅពីលើ នៅក្រោមបទបញ្ជា តា មុ៉ក ។

ធានី : ចឹងដល់ពេលសមាហរណកម្ម ទើបបាន តា ពក ផ្តាច់ខ្លួន?

កូន : បាទ! ផ្តាច់ខ្លួន ។

ធានី : ទៅលោកតាអ៊ីទាំងអស់?

កូន : ដំបូងផ្តាច់ខ្លួនជាមួយ តា ផាន់ អ៊ីនឹងណា ។

ធានី : ចឹងកងទ័ពរបស់លោកតាទៅមុនហើយ?

កូន : បាទ!

ធានី : តែដោយសារគ្រួសារលោកតានៅខាង តា មុ៉ក ក៏រត់មកខាង តា មុ៉ក មកនៅជំរអ៊ីគេ?

កូន : ជំរំភូណាយ ។

ធានី : ភូណាយ?

កូន : បាទ!

ធានី : ចឹងយោធាផ្សេងៗទៅជំរំរបស់ តា ផាន់ អស់ហើយ?

កូន : បាទ! ទៅមួយចំនួន ទៅខាងកើតថ្នល់ ទៅខាងលិចថ្នល់ ៩១២ ទៅនេះ ។

ធានី : បែកគ្នាដាច់ ៩១២ទៅខាង?

កូន : ទៅលើភ្នំ ។

ធានី : ដល់ពេល៩១២ខាងកើត?

គន : ខាង តា ផាន់ នោះផ្តាចខ្លួន ហើយទៅមួយចំណែកត្រពាំងប្រាសាទនេះទៅលើភ្នំទៅ ។

ធានី : អូ! ទៅលើភ្នំផ្សេងទៀត?

កូន : បាទ!

ធានី : លើភ្នំកន្លែង តា មុ៉ក ដដែល?

កូន : បាទ!

ធានី : ហើយដល់ពេលលោកតា ចុះមកវិញ លោកតាមកនៅណា?

កូន : មកនៅនេះ ។

ធានី ៖ ភូមិអូរគគីរក្រោម?

គួន ៖ អរគគីរក្រោម ។

ធានី ៖ មកនៅភូមិនឹងតែម្តង?

គួន ៖ បាទ!

ធានី ៖ យើងចាប់ដីចាប់អី?

គួន ៖ បាទ!

ធានី ៖ តែកាលមុននៅនឹងមានភូមិដែរ?

គួន ៖ ព្រៃ ។

ធានី ៖ អត់ទាន់មានភូមិទេ?

គួន ៖ អត់មានទេ ។

ធានី ៖ ចុះម៉េចបានគេបែកឲ្យមកនៅនឹង?

គួន ៖ គេបែកឲ្យមកនៅនឹង ។

ធានី ៖ គេបែកខាងណា របនាសម្ព័ន្ធគេរៀបយ៉ាងម៉េច លោកតាដឹងទេ?

គួន ៖ គេរៀបឲ្យមកនៅតាមនេះ តាមកងពល ដូច តា គង់ កងពល គេរៀបកម្លាំងឲ្យមកនៅនេះ ។

ធានី ៖ មកនៅនឹង?

គួន ៖ បាទ!

ធានី ៖ ចឹងមានប៉ុន្មានកងពលឃុំលំទងយើងនេះ សុទ្ធតែកងពល?

គួន ៖ មានតែមួយកងពល ។

ធានី ៖ មួយកងពលយើងនៅតែអូរគគីរក្រោម?

គួន ៖ មានដល់លំទង មួយកងពល ប៉ុនឆ្ងាយដល់លំទង ។

ធានី ៖ ចឹងបានន័យថា កងពលរបស់តាគង់នឹង នៅមួយឃុំលំទងយើងនឹង?

គួន ៖ បាទ! ឃុំលំទង ។

ធានី ៖ ហើយ តា គង់ រាល់ថ្ងៃ គាត់នៅរស់ទេ?

គួន ៖ នៅ ។

ធានី ៖ អុំខស្សាប់ជួបគាត់ទេ?

គួន ៖ ជួបម្តងៗ ។

ធានី ៖ ម្តងៗដែលសួរសុខទុក្ខគាត់ទេ?

គួន ៖ អត់ ។

ធានី ៖ ម៉េចចឹង?

គួន ៖ ដូចខ្ជិល ។

ធានី ៖ ម៉េចខ្ជិល មេយើង?

គួន ៖ មេប៉ុនខ្ញុំ គេដោយគេ ខ្ញុំ ។

ធានី ៖ ចុះអ៊ំដូចថាច្បាប់ទម្លាប់នៅភូមិយើងនេះម៉េចដែររាល់ថ្ងៃ?

គួន ៖ ទេ! អត់អីទេ ស្រួល ។

ធានី ៖ ចុះកាលពីមុន?

គួន ៖ ពីមុនមានយើងកាលពីសម័យនោះ អាសម័យយើងបាញ់គ្នាមិនដឹងធ្វើម៉េច ច្បាប់ខុសគ្នា អានោះខុសដៃយកដៃ ខុសជើងយកជើង ប៉ុនម៉ោកឥឡូវពេលនេះ ដូចមិនទាន់មានពួកអ្នកណាសម្លាប់នឹងគេយកទៅវ៉ៃចោល ។

ធានី ៖ អត់មានដែរ?

គួន ៖ អត់ ។

ធានី ៖ ចុះអ៊ំគិតថា តាំងពីសម័យ៣ឆ្នាំ សម័យដែលអ៊ំនៅធ្វើយោធានឹង សម័យកសាងនឹង រហូតមកដល់សម័យតស៊ូ សម័យតាម៉ុកនេះ តើអ៊ំគិតថា មកដល់រាល់ថ្ងៃនឹង ច្បាប់ទម្លាប់នឹងវានៅបន្តមកដល់រាល់ថ្ងៃទៀតអត់?

គួន ៖ អត់ទេ ចប់ ។

ធានី ៖ ចប់ត្រឹមសម័យ តា ម៉ុក ទៅគឺអស់ លែងមានរបបនឹងមកទៀត?

គួន ៖ អត់មាន មានតែសម្ដេច ហ៊ុន សែន ដឹកនាំទៅ ។

ធានី ៖ ចុះអ៊ំឧបមាថា បើកូនអ៊ំសួរថា តា ម៉ុក ជាមនុស្សម៉េច អ៊ំរៀបរាប់ប្រាប់គាត់ថាម៉េចទៅ?

គួន ៖ ប្រាប តា ម៉ុក មនុស្សថាមិនខ្ពស់ៗមិនទាប ។

ធានី ៖ ហើយនិយាយថា ចរិតគាត់?

គួន ៖ អូ! ចរិត កាច តា ម៉ុក គាត់កាចៗស្លូត ឧបមាថាជេរខ្ញុំចេះមានលុយឲ្យ ជេររួចឲ្យ ។

ធានី ៖ អ៊ំធ្លាប់ឃើញ?

គួន ៖ បាទ!

ធានី ៖ ធ្លាប់បានលុយ?

គួន ៖ ទេ! អត់ដែលបានទេ ខ្ញុំឃើញៗ ជេរមីងៗមករកលុយ មុននឹងឲ្យលុយជេរសិន ។

ធានី ៖ ហើយម៉េចទៀតអ៊ំ ក្រៅពីប្រាប់គាត់រឿងនឹង?

កូន ៖ អស់ ។

ធានី ៖ ចុះមានថាកន្លែងនេះកន្លែងអីចឹង តា ម៉ុក គាត់អ្នកផ្ដើម ឬក៏យើងផ្ដើមតាំងពីពេលណាមក?

កូន ៖ តា ម៉ុក ។

ធានី ៖ តា ម៉ុក អ្នកផ្ដើមទាំងអស់?

កូន ៖ បាទ! បែកអង្គរ ចុះយើងមិនទាន់ធ្វើអីបាន ។

ធានី ៖ ចឹង តា ម៉ុក គាត់អ្នកជួយយើងទាំងអស់?

កូន ៖ បាទ! បែកអង្គរ បែកខោអាវ ។

ធានី ៖ សូម្បីតែយើងបែកភូមិអីនេះ គឺ តា ម៉ុក ជួយដែរ?

កូន ៖ បាទ!

ធានី ៖ ប្រាប់កូនចឹង?

កូន ៖ (ស្ដាប់មិនបាន) ។

ធានី ៖ ចឹងអ៊ំចំពោះជីវភាពរបស់អ៊ំ ពីមុនហើយឥឡូវខុសគ្នាម៉េចទៅ ពីមុនយ៉ាងម៉េច ហើយឥឡូវយ៉ាងម៉េច?

កូន ៖ ទេ! នៅតែមធ្យមដដែល ។

ធានី ៖ ពីមុនក៏ចឹង ឥឡូវក៏ចឹងដែរ?

កូន ៖ បាទ! មិនមានដូចគេ មិនជាក្រអីដូចគេ ។

ធានី ៖ ចុះដូចថាទំនាក់ទំនងក្នុងផ្ទះម៉េចដែរ គ្រួសារ អ៊ំជាមួយគ្រួសារជាមួយកូនចៅយ៉ាងម៉េចដែរល្អ?

កូន ៖ អត់អីទេ ។

ធានី ៖ ចុះជាមួយអ្នកជិតខាងអី?

កូន ៖ អត់អី ។ ចាស់គេថានៅស្រុកម្ដាយទីទៃ នៅព្រៃម្ដាយតែមួយ ។

ធានី ៖ ចឹងរិតតែល្អតជាង?

កូន ៖ បាទ!

ធានី ៖ ចុះអ៊ំខស្សប្រាហ៍ទៅលេងផ្ទះដែរ អត់ទេ មើលទៅ?

កូន ៖ ខ្ញុំខាន៦-៧ឆ្នាំហើយ ។

ធានី ៖ ម៉េចចឹង?

គួន ៖ ខ្ញិលនឹងទៅ ។

ធានី ៖ ចុះម្ដាយគាត់នៅរស់ដែរ?

គួន ៖ ស្លាប់អស់ ។

ធានី ៖ ចុះទៅលេងស្រុកទៅលេងនឹង?

គួន ៖ នៅសល់តែបង ។

ធានី ៖ ទៅលេងនឹងបងប្រុស?

គួន ៖ ឃើញតែទៅស្រុក ដូចមិនមានអីនឹងធ្វើស្រែ ដីនៅសល់តែតិច ប៉ុនតែបងគេអ្នកធ្វើ ។

ធានី ៖ ចឹងឪពុកមាយអ៊ំ ទុកដីឲ្យអ៊ំដែរ?

គួន ៖ ទុក ប៉ុនបងគេគ្រប់គ្រង ។

ធានី ៖ តែដីនឹងដីរបស់អ៊ំដដែល ឬដីបង?

គួន ៖ ខ្ញុំប្រគល់ឲ្យបង ។

ធានី ៖ ឲ្យបងម៉ង នៅនេះដីច្រើនជាង?

គួន ៖ បាទ! ទៅដែរ ខ្ញុំទៅរកដីលក់យកទៅធ្វើបុណ្យឲ្យម៉ែឪ ទៅប្រទះគ្នារឿងបង គេថាដីនឹងមិនមែនដីឯង ដីគេ ។ ហើយខ្ញុំថាលក់ដីនឹង ម៉ាសារដីថ្លៃ ។ លក់ដីនឹងធ្វើបុណ្យម៉ែឪ ដល់គេថាឯងប៉ុនមេដៃក៏គេមិនឲ្យ ។ ខ្ញុំក៏មិនទាមទារយកចុះ ។

ធានី ៖ ចឹងទៅក៏លែងទៅជួបគាត់ទៅ ហើយក៏លែងទៅលេងស្រុកទៅ?

គួន ៖ បាទ! បែកបាក់គ្នា ។

ធានី ៖ ហើយមកនៅនេះ យើងមានដីច្រើន?

គួន ៖ ខ្ញុំបានមួយចែកកូន បានកូនម្នាក់បានមួយហត្ថ ។

ធានី ៖ ចឹងកូនមាន៤?

គួន ៖ មាន៦ ប៉ុនគេមាន២នោះគេមានដីខ្លួនគេរកខ្លួនឯង ។

ធានី ៖ ចឹងនៅសល់៤ហត្ថ?

គួន ៖ បាទ!

ធានី ៖ ដី៤ហត្ថ ដីចំការ ហើយដីស្រែ?

គួន ៖ ដីស្រែ ។

ធានី ៖ ហើយដីផ្ទះយើងនៅនេះ ប៉ុន្មានទៅ?

គួន ៖ ដី២០០ បណ្ដោយ ក្បាល៤០ ។

ធានី ៖ ក្រោយនេះយើងធ្វើចំការដែរ?

គួន ៖ បាទ! ដាំដំឡូង ។

ធានី ៖ ចុះអ៊ំនៅពេលដែលនៅផ្ទះជួបគ្នាជាមួយកូនចៅអី ដែលធ្លាប់និយាយពិភាក្សាគ្នារឿងប្រវត្តិសាស្ត្រ និយាយរឿងរ៉ាវអ៊ំប្រាប់ខ្ញុំដែលធ្លាប់និយាយទេ?

គួន ៖ អត់ទេ ។

ធានី ៖ អត់ដែលនិយាយសោះ?

គួន ៖ អត់ ។

ធានី ៖ ចុះអ៊ំឧបមា ដូចខ្ញុំចឹងអត់ដែលស្គាល់ ហើយភ្ញៀវស្រុកផ្សេង ដែលគាត់មិនស្គាល់អន្លង់វែង អ៊ំប្រាប់គេថាម៉េច ដើម្បីឲ្យគេស្គាល់?

គួន ៖ ទេ! បើគេសួរយើងប្រាប់គេ បើសិនជាមិនសួរអត់ ។

ធានី ៖ ចុះបើខ្ញុំសួរថា ខ្ញុំអត់ដែលស្គាល់ចឹង របៀបថា យើងចង់មកលេងអន្លង់វែង យើងចង់មកលេងអីគេ?

គួន ៖ បាទ! គេប្រាប់ថាទៅលេងត្រង់ណាត្រង់ណែ ផ្ទះ តា ម៉ុក ប្រាប់ ។

ធានី ៖ តែចង់និយាយថា អ៊ំអាចប្រាប់គេបានទេ ថានៅអន្លង់វែងមានអីគេខ្លះ?

គួន ៖ ប្រាប់បានតើ ប៉ុនមិនមានអីសំខាន់ គេមានផ្ទះ តា ម៉ុក សសរដើមទ្រាស មានអីសំខាន់ ។

ធានី ៖ ដើមយាង តែប៉ុននឹងអ៊ំ អត់មានអីផ្សេងទៀត?

គួន ៖ បាទ!

ធានី ៖ ចុះអ៊ំគិតថា សៀវភៅដែលខ្ញុំនឹងសរសេរចេញមកនឹងមានប្រយោជន៍អីដល់អ៊ំ? ឬក៏អ៊ំសង្ឃឹមថាគេនឹងសរសេរចេញមកអីគេខ្លះ?

គួន ៖ មិនដឹងសរសេរពីអី ។

ធានី ៖ ចឹងគិតថាសៀវភៅដែលពួកខ្ញុំនឹងសរសេរហើយនឹង មានប្រយោជន៍អីដល់អ៊ំអត់ទេ?

គួន ៖ មិនម៉េចទេ ។

ធានី ៖ ចុះអ៊ំមានអ្នកផ្សេងណាទៀតទេ ដែលខ្ញុំអាចសាកសួរនាំទាក់ទងនឹងប្រវត្តិអន្លង់វែងយ៉េង?

គួន ៖ ម៉ាចំណោមនេះនិយាយថាអួតខ្លួនឯង មានតែខ្ញុំ និង តា ម៉ឺន ទេដឹង ។

ធានី ៖ តា ម៉ឺន នៅលំទងចាស់នឹង?

គួន ៖ បាទ! ដឹងប្រវត្តិរូបអន្លង់វែង ។

ធានី ៖ ហើយមានអ្នកផ្សេងណាទៀតទេ?

គួន ៖ មានខ្លះដែរ ។

ធានី ៖ អ៊ំរកនឹកមើលឈ្មោះអីគេខ្លះ អ៊ំចាំ?

គួន ៖ ឈ្មោះ អា សៀន នៅតាដេវ ។

ធានី ៖ សៀន អីសៀន?

គួន ៖ អត់ស្គាល់នាមត្រកូលគេដែរ ។

ធានី ៖ សៀន នឹងគាត់ជាអ្នកណាគេបាន?

គួន ៖ ទាហានចាស់ ដុំខ្ញុំ ។

ធានី ៖ ប្រពន្ធគាត់ឈ្មោះអីគេ?

គួន ៖ ឈ្មោះ ឡាន ។

ធានី ៖ មានតែ៣នាក់នឹងទេ?

គួន ៖ បាទ! ស្លាប់អស់ហើយ ។

ធានី ៖ ចុះលោកតាមានសល់រូបថត ឬឯកសារអីចាស់ៗ សម្ភារៈអី?

គួន ៖ អត់ទេ អត់ដែលមាន ។

ធានី ៖ ចុះដូចជាកាដុងទឹក ឬខោអាវចាស់ៗ ដែល តា ម៉ុក ចែកឲ្យចឹង តាំងយោធា ព្រោះលោកតានៅយោធា?

គួន ៖ អត់មាន បោសសំអាតទាំងអស់ ។

ធានី ៖ ម៉េចចឹងយកទៅណាទៅចឹង កាលមុន?

គួន ៖ ឲ្យគេអស់ ឈប់ទាហាន ឈប់ទាំងអស់ ។

ធានី ៖ ឈប់ទាំងអស់ម៉ង?

គួន ៖ បាទ!

ធានី ៖ អត់មាននៅសល់អី?

គន ៖ អត់មានគេរតំណែលរូបថតអីក៏អត់មាន ។

ធានី ៖ ធ្លាប់ថតដែរ?

គួន ៖ ថត ។

ធានី ៖ ម៉េចបានអត់មាន?

គួន ៖ អត់ទុក មិនចាប់អារម្មណ៍អានឹង រូបថត ។

ធានី ៖ ជាវត្ថុ ជាដាវ ជាស្អីៗ?

គួន ៖ អត់មានទេ ។

ធានី ៖ អស់រលីង?

គួន ៖ ថាបោសសំអាតៗទាំងអស់ ។

ធានី ៖ អ្នកណាគេថាបោសសំអាត?

គួន ៖ ទេ! ថាខ្លួនឯង ។

ធានី ៖ ពេលក្រោយសមាហរណកម្មហើយ?

គួន ៖ បាទ!

ធានី ៖ ចុះលោកតាមានអីចង់សួរខ្ញុំវិញទេ?

គួន ៖ អត់ទេ ។

ធានី ៖ ចឹងអរគុណ ។

គួន ៖ បាទ!

ធានី ៖ អរគុណលោកតាច្រើនដែលបានផ្តល់កិច្ចសម្ភាសន៍ ។

«ចប់»